# ព្រឹត្តិបត្រមេធាវី
# លេខ ២៥
# ខែ មេសា-មិថុនា ឆ្នាំ ២០២០

រក្សាសិទ្ធិ © 2020 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនឆ្លុះបញ្ចាំង នូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាព នៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

ទំព័រ

# មាតិកា


**សាររបស់ប្រធានគណៈមេធាវី** ........ III

## ព្រហ្មទណ្ឌ

**ធាតុផ្សំអត្តនោម័ត** (Mens Rea) ........ 1

១. សេចក្តីផ្តើម ........ 1

២.ខ្លឹមសារ ........ 1

២.១. កម្ពុជា ........ 1

២.២. បរទេស ........ 2

៣. សង្ខេប ........ 7

**ឃាតកម្មគិតទុកជាមុន** ........ 9

១. សេចក្តីផ្តើម ........ 9

២. ខ្លឹមសារ ........ 12

២.១ បទប្បញ្ញត្តិច្បាប់ ........ 12

២.២. ធាតុផ្សំនៃបទល្មើស ........ 12

២.៣. យោបល់អ្នកជំនាញ យុត្តិសាស្ត្រ និងច្បាប់បរទេស ........ 14

៣. សង្ខេប ........ 16

**លំហូរនីតិវិធីព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌** .. 17

សេចក្តីផ្តើម ........ 17

I. បណ្តឹង ........ 17

II. ដំណើរការនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ 22

## រដ្ឋប្បវេណី

**នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ........ 33

សេចក្តីផ្តើម ........ 33

១.អត្ថន័យនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ........ 34

២.ការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ........ 34

៣.ការចាត់តាំងចៅក្រមទទួលបន្ទុកដោយប្រធានសាលាដំបូង.................................37
៤.ការពិនិត្យពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន .....................................37
៥.ការធ្វើសេចក្តីបញ្ជាក់ដំបូង............................................................................38
៦.ការពិនិត្យល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន ...........................................39
៧.ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន.................................................41
៨.ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ........................................................42
៩.បណ្តឹងឧបាស្រ័យ .......................................................................................43
១០.ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ........................................46
សេចក្តីសន្និដ្ឋាន .........................................................................................47

## សកម្មភាពរបស់គណៈមេធាវី

១.ទំនាក់ទំនងជាតិ និងអន្តរជាតិ.....................................................................51
១.១ ទំនាក់ទំនងជាតិ.......................................................................................51
១.២ ទំនាក់ទំនងអន្តរជាតិ..................................................................................58
២. ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា ........................................................66

# សាររបស់ប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា មានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ២៣ សម្រាប់ត្រីមាសទី២ ខែមេសា-មិថុនា ឆ្នាំ២០២០។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធម្នាក់ៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់ ។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែក វិភាគទានអត្ថបទរបស់ខ្លួន ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធាន បុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតារជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី២ "ពង្រឹង និងការពារវិជ្ជាជីវៈ" នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើ សេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជា

និច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **កុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **ទ៉ា សំរិត** តាមអ៊ីម៉ែល samrit@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ព្រហ្មទណ្ឌ

# ធាតុផ្សំអត្តនោម័ត (Mens Rea)

ដោយ បណ្ឌិត មាស ប៊ូរ៉ា និងលោក ចក សម្បត្តិ*

## ១. សេចក្តីផ្តើម

ជាទូទៅ អ្នកសិក្សាច្បាប់ព្រហ្មទណ្ឌដឹងថា មានធាតុផ្សំនៃបទល្មើសយ៉ាងតិចចំនួនពីរ គឺ ធាតុផ្សំសម្ភារៈ និងធាតុផ្សំអត្តនោម័ត។ មានការដឹង និងស្រួលយល់ អំពីធាតុផ្សំទីមួយ ក៏ប៉ុន្តែ មានការលំបាកយល់ អំពីធាតុផ្សំទី២ ដែលមានលក្ខណៈអរូបី និងមានពាក្យជាច្រើន ត្រូវបានប្រើ ដើម្បីបង្ហាញពីធាតុផ្សំអត្តនោម័ត។ វាពាក់ព័ន្ធស្ថានភាពផ្លូវចិត្តរបស់ជនល្មើស ដូចជា មានចេតនាជាដើម។

អត្ថបទខ្លីនេះ មានបំណងបង្ហាញត្រឹមតែជាសញ្ញាណ នៃធាតុផ្សំអត្តនោម័ត ដោយផ្តល់នូវភាពខុសគ្នារវាងខ្លឹមសារនៃពាក្យ និងកម្រិតនៃធាតុផ្សំនេះ។ អត្ថបទនេះចាប់ផ្តើម ពិនិត្យមើល មាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃប្រទេសកម្ពុជា និង ពាក្យពេចន៍ ដែលត្រូវបានប្រើក្នុងក្រមនេះ មុននឹងពិនិត្យមើលទ្រឹស្តី យុត្តិសាស្ត្រ ឬច្បាប់បរទេស។

## ២.ខ្លឹមសារ

### ២.១. កម្ពុជា

ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានរំលេចនូវពាក្យសំដែង ពីធាតុផ្សំអត្តនោម័ត ក្នុងមាត្រាជាច្រើន ហើយមាត្រា៤ ស្តីពី ចេតនាប្រព្រឹត្តបទល្មើស ដែលជាមាត្រាចំបង បានចែងថាៈ

"ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយ អាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។"[1]

តាមខ្លឹមសារនៃមាត្រាខាងលើ ក្រៅពីពាក្យ "ចេតនា" នៅមានពាក្យ "មិនប្រុងប្រយ័ត្ន" "ខ្ជីខ្ជា" "ការធ្វើប្រហែស" ឬ"ការមិនគោរពកាតព្វកិច្ច" ដែលជាពាក្យដែលសំគាល់ ធាតុអត្តនោម័ត។

មាត្រាមួយចំនួន នៃក្រមដដែល ដូចជាមាត្រា ២៩ ជាដើម ការប្រើពាក្យ "ចេតនា" សំដៅដល់ដល់ការប៉ុនប៉ង ឬការសម្រេចបទល្មើស (អ្នកសមគំនិត)ផងដែរ។ មាត្រា ១៩៣ ស្តីពីទារុណកម្ម ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម ប្រើពាក្យ អំពើបង្កដោយ "ចេតនានូវការឈឺចាប់"។ បទមនុស្សឃាត មាត្រា ១៩៩ ប្រើពាក្យ "សម្លាប់ដោយចេតនា"។ មាត្រា ៧៩ ប្រើពាក្យ ការប្រើប្រាស់កូនសោ

---

* លោក មាស ប៊ូរ៉ា ជាអ្នកស្រាវជ្រាវច្បាប់។ លោក ចក សម្បត្តិ ជាព្រះរាជាអាជ្ញារង នៃសាលាដំបូងខេត្តព្រះវិហារ។

[1] Article 4 Intent: There shall be no offence in the absence of intent to commit it. However, where so provided by law, an offence may result from recklessness, carelessness, negligence or failure to fulfil a specific obligation, ក្រមព្រហ្មទណ្ឌ ភាសាខ្មែរ និងអង់គ្លេស ដោយ លោក ជឹង ប៊ុនឡេង ឆ្នាំ ២០១១។

ដែលបានមក"ដោយឧបាយកលទុច្ចរិត"។ មាត្រា ១៨៣ ស្តីពី បទប្រល័យពូជសាសន៍ ប្រើពាក្យ "ក្នុងគោលបំណងបំផ្លាញទាំងមូល" និង "សំដៅរារាំងកំណើតទារកក្នុងក្រុម"។ រីឯ មាត្រា ៣៣០ (បទញុះញង់ឲ្យបោះបង់ទារក) ប្រើឃ្លា "ក្នុងគោលដៅចង់បានកម្រៃ" និងជាចុងក្រោយ គឺមាត្រា ៣៨៤ ស្តីពីបទបន្លំ បានប្រើពាក្យ "ដឹងថាខ្លួនគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ"។

មាត្រាដកស្រង់ខាងលើ ភាគច្រើនប្រើពាក្យ ចេតនា គោលបំណង (សំដៅ ឬគោលដៅ) និងចុងក្រោយ គឺ ដឹង។ ករណីនេះ ប្រសិនបើជនល្មើស បានដឹងតែនៅប្រព្រឹត្ត នោះពិតជាបំពេញបានធាតុផ្សំអត្តនោម័តហើយ។ គេអាចសន្និដ្ឋានបានថាមានបទល្មើសតិចតួចណាស់បង្ហាញពីធាតុផ្សំអត្តនោម័ត។ ផ្សេងពីនេះ មេធាវី ចៅក្រម ព្រះរាជអាជ្ញា គួរពិចារណាច្បាប់ ឬយុត្តិសាស្ត្រដទៃដើម្បីបញ្ជាក់ថា ធាតុផ្សំអត្តនោម័តនៃបទល្មើសនេះជាអ្វី។

## ២.២. បរទេស

### ២.២.១. បារាំង

ដោយសារ ក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានអះអាងថា បានយកតាមខ្លឹមសារ នៃក្រមព្រហ្មទណ្ឌ បារាំង អ្នកនិពន្ធ សូមលើកយកសញ្ញាណ ក្នុងច្បាប់បារាំង និង បង្ហាញដោយអ្នកជំនាញច្បាប់ព្រហ្មទណ្ឌបារាំង។ អ្នកនិពន្ធ សូមដកស្រង់ មាត្រា នៃក្រមព្រហ្មទណ្ឌបារាំង ដែលមានខ្លឹមសារស្រដៀងមាត្រា ៤..."However, when law so provides, a major offence can be committed by imprudence, negligence or by deliberately putting another in danger"។[2]

ទោះបីជាយ៉ាងនេះ មានតែពាក្យមួយចំនួនពាក់ព័ន្ធ ដែលត្រូវបានបំភ្លឺ ក្នុងបរិបទ មនុស្សឃាតអចេតនា។ បទល្មើសអាចប្រព្រឹត្ត ដោយសារមិនបានបំពេញវិជ្ជាជីវៈត្រឹមត្រូវ (គ្មានជំនាញ)។ អ្នកនិពន្ធបានប្រើពាក្យរួមបញ្ចូលគ្នា Carelessness, Inattention or Negligence សំដៅក្នុងករណីដែលគ្រូពេទ្យ មិនបានផ្តល់ការពិនិត្យគ្រប់គ្រងលើអ្នកជំងឺ រួមជាមួយនឹង ការអាចមើលឃើញដឹងអំពីការខូចខាតនាពេលខាងមុខ។ ពាក្យ «Inattention or Negligence» ប្រើក្នុងករណីដូចជា កង្វះវិធានការសន្តិសុខ ក្នុងការគ្រប់គ្រងទីតាំងអគារ ការបំពានដោយចេតនាជាមុននូវកាតព្វកិច្ចសន្តិសុខដោយនាយកក្រុមហ៊ុន ដែលមើលរំលង (ignore) នូវការព្រមានជាផ្លូវការអំពីសុខភាព និងសុវត្ថិភាពក្រោយពីការធ្វើអធិការកិច្ចជាចុងក្រោយការខកខានគោរពតាមវិធានដែលរាប់បញ្ចូលវិធានផ្ទៃក្នុងរបស់

---

[2] Article 121-3 of France, quoted in Catherine Elliott, French Criminal Law, 2001, p.65.

ក្រុមហ៊ុនផងដែរ។ ក៏ប៉ុន្តែ ក្រោយមក លុះត្រាតែវាជាការបំពានក្រឹត្យ ឬបទបញ្ជាផ្លូវការរបស់មន្ត្រីទើបគ្រប់គ្រាន់នាំឲ្យមានការទទួលខុសត្រូវ។[3]

## ២.២.២. ប្រភេទផ្សេងទៀត

វាក្យស័ព្ទច្បាប់មានជាច្រើនត្រូវបានប្រើ ដើម្បីសំគាល់ធាតុផ្សំអត្តនោម័តនេះ ដូចជា ចេតនាដឹង (knowledge) មានគោលបំណង (purpose) ធ្វេសប្រហែស (negligence) ការមិនប្រុងប្រយ័ត្ន (recklessness) ចេតនាទុច្ចរិត (malice) ជាដើម។[4] ពាក្យទាំងនេះ មានខ្លឹមសារ មិនច្បាស់ទេ ហើយយុត្តាធិការខ្លះ មិនចាត់ពាក្យខ្លះ បង្ហាញពីធាតុផ្សំផងដែរ។[5] ច្បាប់ ឬយុត្តិសាស្ត្រ បរទេសខ្លះ ផ្តល់កម្រិតនៃធាតុផ្សំអត្តនោម័តមួយទាបជាងមួយ ឬបញ្ច្រាសគ្នា។ បន្ថែមពីនេះ ថាតើជាតុផ្សំទាំងនេះគួរត្រូវបានពិចារណាតាមអត្តនោម័ត (subjective) ឬ សត្យានុម័ត (objective approach) ក៏នៅមានភាពមិនច្បាស់ផងដែរ។[6]

ជាទូទៅ បទល្មើសទាមទារនូវធាតុអត្តនោម័ត ក៏ប៉ុន្តែក៏មានករណីលើកលែងខ្លះផងដែរ។ បទល្មើសមួយចំនួន ទាមទារធាតុផ្សំសម្ភារៈតែប៉ុណ្ណោះ (Strict Liability Offense) ដូចជាក្នុង វិស័យចរាចរណ៍ផ្លូវគោក។[7] យុត្តាធិការទាំងអស់ ឯកភាពថា ចេតនា គឺជាធាតុផ្សំអត្តនោម័ត។ ខណៈដែលការធ្វេសប្រហែស និង ជាពិសេស ការមិនប្រុងប្រយ័ត្ន ឬខ្ជីខ្ជា មិនត្រូវបានចាត់ថាជាធាតុផ្សំអត្តនោម័តទេ ក្នុងក្រមព្រហ្មទណ្ឌប្រទេសមួយចំនួន។

ចេតនា៖ ចេតនាត្រូវបានផ្តល់ន័យថា ការចង់បានអ្វីដូចដែលជនល្មើសប៉ងប្រាថ្នា។ ជនល្មើសដឹងថាបេះដូងជាសរីរាង្គសំខាន់ លើកកាំភ្លើងបាញ់ចំបេះដូងជនរងគ្រោះ ជនរងគ្រោះបានស្លាប់។ នេះជាឧទាហរណ៍ដ៏សាមញ្ញមួយ អំពីអ្វីទៅជាចេតនា។ ចេតនានេះ ជាចេតនាផ្ទាល់ (direct

[3] Id., pp.161-162.

[4] Recklessness ត្រូវបានបកប្រែជា ការមិនប្រុងប្រយ័ត្ន, ក្រមព្រហ្មទណ្ឌ ភាសាខ្មែរ និងអង់គ្លេស ដោយ លោក ជឹង ប៊ុនឡេង ឆ្នាំ ២០១១, មាត្រា ២០៧។

[5] French and German Criminal Laws prefer “negligence”, Catherine Elliott, supra note 2, pp.64-83, 745; Michael Bohlander, Principle of German Criminal Law, 2009, p. 63.

[6] Simon Bronitt, Australia in Kevin Jon Heller and Markus D. Dubber, the Handbook of Comparative Criminal Law, 2011, p. 58.

[7] Joshua Dressler, Understanding Criminal Law, 2009, p. 145.

intent)។[8] ជនម្នាក់ បានចោលដំថ្មបំបែកកញ្ចក់បង្អួច ចេតនាដើម្បីឲ្យកញ្ចក់ធ្លាក់ត្រូវក្បាលមនុស្ស នៅខាងក្រោម។ នេះបង្ហាញពីចេតនាដោយប្រយោល (indirect intent)។ នេះទំនងដូចជា ចេតនា មានលក្ខខ័ណ្ឌ (conditional intent) ដែលអះអាងដោយយុត្តាធិការ អាឡឺម៉ង់។[9] វាក៏មានដែរនូវ ចេតនា ជាមុន (aforethought intent)។[10] ជាទូទៅ ចេតនាត្រូវកើតឡើងព្រមគ្នាឬជូនគ្នានឹងសកម្មភាព។ ប្រសិនមិនដូចនេះទេ វាអាចមិនមែនជាបទល្មើសដូចដែលបានចោទឡើង។

អ្នកស្រាវជ្រាវ គួរញែកពាក្យ "មូលហេតុ (motive)" និង"ចេតនា"។ ពាក្យនេះមិនដូចគ្នាទេ។ Motive នាំឲ្យមានចេតនា ហើយការសំអាងលើ Motive មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ឧទាហរណ៍ គ្រូពេទ្យ តាមសំណើរបស់អ្នកជំងឺរ៉ាំរ៉ៃ ដោយមូលហេតុអាណិត បានចាក់ថ្នាំសម្លាប់អ្នកជំងឺ។ គ្រូពេទ្យនៅតែមានចេតនាសម្លាប់[11] ដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងបទណាមួយជាមួយនឹងស្ថានសម្រាល អនុលោមតាមច្បាប់នៃប្រទេសនីមួយៗ។

ចេតនានេះទៀត ត្រូវបានបែកចែកជាទូទៅ (general intent) និងជាក់លាក់ (specific intent)។ ចេតនាទូទៅ មានធាតុផ្សំចំណង់ (desire) និង បានដឹង (aware)។[12] បទរំលោភសេពសន្ថវៈ ត្រូវបានចាត់ថាទាមទារត្រឹមតែចេតនាទូទៅ។ ជនល្មើសចង់បំពេញចំណងផ្លូវកាម និងដឹងថាការរំលោភសេពសន្ថវៈគឺខុសច្បាប់ តែគាត់នៅតែប្រព្រឹត្ត។ ចេតនាពិសេស គឺហួសពីចេតនាទូទៅ ព្រោះទាមទារឲ្យសម្រេចបំណងអ្វីមួយជាក់លាក់។ នេះចូលក្នុងករណីបទលួចទ្រព្យ។ ជនល្មើសចង់បានទ្រព្យយកមកជារបស់ខ្លួន។

ការមិនប្រុងប្រយ័ត្នៈ មានទង្វើជាច្រើនបង្កផលវិបាកដល់សង្គម ដែលច្បាប់ត្រូវចាត់វិធានការ ដើម្បីការពារសុវត្ថិភាព ឬសន្តិសុខរបស់ប្រជាពលរដ្ឋ តាមរយៈការចែងជាបទល្មើស ទាមទារនូវធាតុផ្សំអត្តនោម័ត (ចេតនា) ឬ ការធ្វេសប្រហែស។ ក្នុងករណីខ្លះ ធាតុផ្សំមិនមានចែង ដូចនេះ ការមិនប្រុងប្រយ័ត្ន ត្រូវបានយោង ឬប្រើប្រាស់ដើម្បីបំពេញចំណុចខ្វះខាត។

វាសំដែងឲ្យដឹងតាមសកម្មភាព ដែលបង្កហានីភ័យ ដែលជនល្មើសបានដឹង ក៏ប៉ុន្តែមិនខ្វល់ និងនៅតែធ្វើសកម្មភាព។ ក្នុងន័យនេះ វាបង្ហាញថា ជនល្មើសដឹងហើយនៅតែបន្តឬធ្វើសកម្មភាព។ នេះបង្ហាញពី ចិត្តទុច្ចរិត (guilty mind)។ ឧទាហរណ៍ នៅក្នុងរង្គសាលមួយមានមនុស្សជាច្រើន

[8] អ្នកស្រាវជ្រាវខ្លះ ឲ្យឈ្មោះថាជាចេតនាតាមអង្គហេតុ (factual intent) ដែលខុសគ្នា នឹង Legal intent (បង្ករបួសជាមួយហានីយភ័យថា នឹងនាំឲ្យស្លាប់) សូមមើល G. Feltoe, Commentary on Criminal law, 2012, p. 60; Catherine Elliott and Frances Quinn, Criminal Law, 6th ed., 2006, p.16.

[9] Michael Bohlander, supra note 5, p. 49.

[10] L. Radzinowicz, Mens Rea in Statutory Offences, 1955, p.12.

[11] Catherine Elliott and Frances Quinn, supra note 8, p. 26.

[12] L. Radzinowicz, supra note 10, pp.16-17.

ដែលកំពុងរាំច្រៀង ជនល្មើសបានយកគ្រាប់ភ្លើងបាញ់តាមបង្អួចកញ្ចក់ចូលទៅក្នុង បន្ទប់រង្គសាល ដែលមានមនុស្សអ៊ូអរ។ នោះបង្ហាញនូវហានីភ័យខ្ពស់ តែជនល្មើសមិនខ្វល់ពីអ្វីកើតឡើង។

អត្ថបទសូមដកស្រង់ខ្លឹមសារដ៏ល្អមួយអំពី ការមិនប្រុងប្រយ័ត្ន ៖ បុគ្គលម្នាក់មិនប្រុងប្រយ័ត្ន បើ ១. គាត់បានប្រព្រឹត្ត បង្កនូវហានីភ័យធ្ងន់ធ្ងរ ដែលទ្រព្យសម្បត្តិ អាចត្រូវបានបំផ្លាញ ឬខូចខាត និង ២. នៅពេលគាត់បានប្រព្រឹត្តដោយគ្មានគិតពិចារណា នូវលទ្ធភាពដែលអាចមានហានីភ័យ ដែលការពិតហានីភ័យនឹងកើតមាន ឬ ទទួលស្គាល់ថាមានហានីភ័យពាក់ព័ន្ធ ក៏ប៉ុន្តែនៅតែប្រព្រឹត្តទង្វើណាមួយនោះ។[13]

ផ្អែកលើឧទាហរណ៍ខាងលើ អ្នកស្រាវជ្រាវខ្លះ បានអះអាងថា ការមិនប្រុងប្រយ័ត្ន ស្រដៀង ឬលើសកម្រិតជិតស្មើ និងចេតនា។ ការមិនប្រុងប្រយ័ត្ន ស្មើនឹងការធ្វេសប្រហែសដ៏ធ្ងន់ធ្ងរ (gross negligence)។ យុត្តាធិការប្រទេសខ្លះ ឲ្យកម្រិត ការមិនប្រុងប្រយ័ត្ន ទាបជាងការធ្វេសប្រហែល។ ក៏ប៉ុន្តែ ប្រសិនគេទទួលយកឧទាហរណ៍នេះ ត្រឹមត្រូវឆ្លុះនឹងធាតុអត្តនោម័ត ការមិនប្រុងប្រយ័ត្ន អ្នកនិពន្ធអត្ថបទនេះ ឯកភាពថា ការមិនប្រុងប្រយ័ត្នខ្ពស់ជាងការធ្វេសប្រហែស។ ការបែងចែក ឬ ដាក់កម្រិតលំដាប់ថ្នាក់ពិតជាសំខាន់ ពីព្រោះបទល្មើសខ្លះទាមទារនូវប្រភេទនៃធាតុផ្សំអត្តនោម័តខុសគ្នា ហើយព្រះរាជអាជ្ញា ត្រូវបង្ហាញធាតុផ្សំនេះ។ បន្ថែមពីលើនេះ កម្រិតធាតុផ្សំអត្តនោម័ត ពាក់ព័ន្ធជាមួយនឹងការកំណត់ទោស។ ជាក់ស្តែង ចេតនាផ្ទាល់ អាចនាំឲ្យមានទោសធ្ងន់ក៏អាចថាបាន ដោយមិនគិតពីភាពងាយស្រួលក្នុងការបង្ហាញធាតុផ្សំនេះ។

ការធ្វេសប្រហែស៖ ជាការចាប់ផ្តើម សូមកុំច្រឡំវានឹងចេតនាមិនផ្ទាល់ដែលបរិយាយខាងលើ។ វាមានប្រភពពីវិស័យរដ្ឋប្បវេណី ពោលគឺ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល (tort) ដោយសារការធ្វេសប្រហែស។ ទោះបីជាយ៉ាងនេះក្តី ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ កម្រិតធ្ងន់ធ្ងរនៃទង្វើ ត្រូវខ្ពស់ជាងសម្រាប់ការទទួលខុសត្រូវខាងរដ្ឋប្បវេណី។ ទំនងជាមូលដ្ឋាននេះហើយទើបរដ្ឋខ្លះ ដែលបរិយាយក្នុងអត្ថបទនេះ ទាមទារហួសពីការធ្វេសប្រហែសធម្មតា (mere negligence)។[14] ការធ្វេសប្រហែស ត្រូវតែធំធេង ឬធ្ងន់ធ្ងរ។ យុត្តិសាស្ត្រអាឡឺម៉ង់បានប្រើពាក្យ «ការធ្វេសប្រហែសជាសម្បជញ្ញៈ» (conscious negligence)។

---

[13] A person will be reckless if (1) he or she does an act which in fact create a serious risk that property would be destroyed or damaged and (2) either (a) when he or she does the act he or she has not given any thought to the possibility of there being any such risk, and the risk was in fact obvious; or (has recognized that there was some risk of that kind involved and has nonetheless gone on to do it, quoted in para 44 of Rigna v. G and another, House of Lords, 16 October 2003.

[14] Kent Roach, Canada in Kevin Jon Heller, supra note 6, p. 107.

អ្វីខុសគ្នារវាងការមិនប្រុងប្រយ័ត្ន និង ការធ្វេសប្រហែស គឺថាក្នុងករណីការមិនប្រុងប្រយ័ត្ន ជនល្មើសដឹង ច្បាស់ថាមានហានីភ័យ។ ចំណែក ការធ្វេសប្រហែស ជនល្មើសមិនដឹងហានីភ័យច្បាស់ទេ។ ជាមួយគ្នា នេះដែរ សូមកុំច្រឡំរវាងការធ្វេសប្រហែស និង ការខកខាន ឬអសកម្មភាព (omission) ដែលគេរាប់បញ្ចូលក្នុងធាតុផ្សំសម្ភារៈនៃបទល្មើស។ ការខកខាន ជាបទល្មើសព្រហ្មទណ្ឌ។[15] ការធ្វេសប្រហែលជាធាតុផ្សំអត្តនោម័តនៃបទល្មើស ។

ដោយសារ វាមានប្រភពពី អំពើអនីត្យានុកូល គេត្រូវកំណត់ជាមុនសិន ថាតើអ្នកប្រព្រឹត្តមានករណីកិច្ចប្រុងប្រយ័ត្ន (Duty of Care) លើជនរងគ្រោះដែរឬទេ។[16] ជនល្មើសបានបំពានករណីកិច្ចនោះ ហើយធ្វើឲ្យជនរងគ្រោះមានហានីភ័យ។ ហានីភ័យត្រូវតែខ្ពស់ (great short of reasonable standard)។ ប្រទេសខ្លះ បានចែងអំពី បទសម្លាប់មនុស្សដោយការធ្វេសប្រហែសធ្ងន់ធ្ងរ (gross negligent manslaughter)[17] ការបើកបរធ្វេសប្រហែស នាំឲ្យមនុស្សស្លាប់។[18] វេជ្ជបណ្ឌិត មានករណីកិច្ចពិនិត្យ និងថែទាំ ព្យាបាលអ្នកជំងឺ។ ប្រសិនបើគាត់ទុកអ្នកជំងឺចោលដោយមិនពិនិត្យ ថែទាំង និងព្យាបាល នោះនឹងនាំឲ្យអ្នកជំងឺស្លាប់។ គាត់អាចត្រូវបានចោទពីបទសម្លាប់មនុស្ស ដោយការធ្វេសប្រហែស។[19] ឧទាហរណ៍បន្ថែម ដើម្បីវះកាត់អាចប្រព្រឹត្តទៅបាន គឺទាមទារនូវស្តង់ដាប្រតិបត្តិ X ក៏ប៉ុន្តែគ្រូពេទ្យមិនបានបំពេញតាមទេ ឬធ្វើ
ទាបជាងស្តង់ដា។

ដើម្បីបង្ហាញនូវ ការធ្វេសប្រហែស យុត្តិសាស្ត្របានប្រកាន់យកនូវវិធីសាស្ត្រ មនុស្សមានហេតុផល (reasonable person) ដែលជាវិធីសាស្ត្រសត្យានុម័ត (objective test)។[20] មនុស្សមានហេតុផល ក្នុងស្ថានភាពដែលជនល្មើសកំពុងប្រឈម តើត្រូវឆ្លើយតបយ៉ាងដូចម្តេច?។ ទោះបីជាយ៉ាងនេះក្តី វាមិនសុក្រឹត្យទេ បើមិនពិចារណានូវកត្តាដទៃទៀត ដូចជា អាយុ ស្ថានភាពសុខភាព ឬបរិស្ថានជុំវិញរបស់ជនល្មើស។ ឧទាហរណ៍ ក្នុងករណី ក្មេងលេងភ្លើង បង្កឲ្យឆេះផ្ទះគេ។ ស្តង់ដា

---

[15] Only duty, imposing duty reasonable, failure to give food to child and died, mother is criminal responsible, Matthew Lippman, Contemporary Criminal Law, 2010, p.97.

[16] At present I content myself with pointing out that in English law there must be, and is, some general conception of relations giving rise to a duty of care … The liability for negligence, …, be treated so as to give a right to every person injured by them to demand relief. In this way rules of law arise which limit the range of complainants and the extent of their remedy. The rule that you are to love your neighbor becomes in law,... You must take reasonable care to avoid acts or omissions which you can reasonably foresee would be likely to injure your neighbor, *Donoghue v Stevenson*, 1932 SC (HL) 31 (UKHL 26 May 1932).

[17] Catherine Elliott, supra note 8, p. 111.

[18] Catherine Elliott, supra note 8, pp. 111-112.

[19] ខុសពីសម្លាប់មនុស្សដោយអចេតនា (អចេតនា រាប់បញ្ចូលធ្វេសប្រហែស)។

[20] ពិចារណា ការឆ្លើយតប របស់មនុស្សមានហេតុផល ក្នុងស្ថានភាពដូច ដែលជនល្មើសជួប។ Catherine Elliott and Frances Quinn, supra note 8, p. 19.

មនុស្សមានហេតុផលមិនអាចត្រូវបានអនុវត្តទេ ដោយសារក្មេងយល់ដឹងតិចតួច ឬ មិនសូវមានហេតុផលផង។

មុននឹងបញ្ចប់ អត្ថបទសូមលើកយកទ្រឹស្តីចំនួនពីរ ដែលពាក់ព័ន្ធ៖ ទី១. ការផ្ទេរចេតនា (transfer of malice) និងទី២ ធាតុផ្សំអត្តនោម័តត្រូវបានសន្មត់ (constructive mens rea)។ ទី១. អនុវត្តចំពោះការសម្លាប់មនុស្ស ខុសពីគោលដៅ។ ជនល្មើស ចង់សម្លាប់ ក តែបែរជាបាញ់សម្លាប់ ខ។ នេះជាការផ្ទេរចេតនា សម្លាប់ ក ទៅ ជាចេតនាសម្លាប់ ខ។[21] ទីពីរកើតមានក្នុងបទល្មើស នៃប្រទេសកុំមុនឡ ដូចជា Felony-Murder (សម្លាប់នារីរងគ្រោះក្នុងអំឡុងពេលរំលោភសេពសន្ថវៈ)។ ចេតនា របស់ជនល្មើស គឺ រំលោភសេពសន្ថវៈ។ តាមទ្រឹស្តីនេះ ចេតនារំលោភ នាំឲ្យសន្និដ្ឋានថាមានចេតនាសម្លាប់។[22] វាជារឿងចម្រូងចម្រាស់ អាស្រ័យហេតុនេះ ប្រទេសខ្លះមិនប្រកាន់យកទៀតទេ។[23]

## ៣. សង្ខេប

ឃាតកម្មគិតទុកជាមុន ជាការសម្លាប់មនុស្សដោយចេតនា បង្ហាញតាមរយៈគម្រោង ឬផែនការប្រព្រឹត្ត ដើម្បីសម្រេចតាមការរំពឹងទុក។ ជនរងគ្រោះត្រូវតែជាមនុស្សមានជីវិត ទោះបីប៉ុន្មាននាទីមុខសកម្មភាពសម្លាប់កើតឡើងក្តី។ យុត្តិសាស្ត្របានបង្ហាញថា ពេលណា ដែលជីវិតត្រូវបានចាត់ថា បញ្ចប់ នោះគឺការឈប់ដំណើរការនៃខួរក្បាល។ នៅមានបញ្ហា ស្មុគ្រស្មាញក្នុងការបែងចែកមនុស្សឃាត និងក៏ប៉ុនប៉ងប្រព្រឹត្តមនុស្ស ដែលអ្នកសិក្សា ក្រោយៗ គួរបន្តស្រាវជ្រាវ តាមរយៈការលើកអង្គហេតុជាក់ស្តែង ជាឧទាហរណ៍ ដើម្បីបំភ្លឺ Gray Zone។

[21] Catherine Elliott, supra note 8, p. 25.
[22] Catherine Elliott, supra note 8, pp. 25-26.
[23] Thomas Weigend, Germany in Kevin Jon Heller, supra note 6, p. 277.

# ឃាតកម្មគិតទុកជាមុន

ដោយបណ្ឌិត មាស បូរ៉ា*

## ១. សេចក្តីផ្តើម

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ចែងអំពីអំពើសម្លាប់មនុស្ស ក្នុងទម្រង់នៃការប្រព្រឹត្តដោយចេតនា ឬអចេតនា បន្ថែមលើបទល្មើសសម្លាប់មនុស្សផ្សេងទៀត ដែលក្រមព្រហ្មទណ្ឌកំណត់ជាការសម្លាប់ជាក់លាក់ដោយកំណត់តាមប្រភេទនៃជនរងគ្រោះ ដូចជា សម្លាប់ព្រះមហាក្សត្រ (បទរាជឃាតកម្ម[24]) ជាដើម។ ជាទូទៅ អំពើសម្លាប់មនុស្សនេះត្រូវទទួលរងនូវទោសទណ្ឌយ៉ាងធ្ងន់ធ្ងរ ហើយទាមទារនូវការកំណត់និយមន័យ និងធាតុផ្សំនៃបទល្មើសឲ្យបានជាក់លាក់ ដើម្បីកាត់បន្ថយនូវការកំណត់ ចាត់ថ្នាក់បទល្មើសប្រភេទនេះដោយច្រឡំ ជាយថាហេតុ ដែលនាំឲ្យជនល្មើស ដែលសមទទួលទោសធ្ងន់ បែរជាទទួលទោសស្រាល ឬជនល្មើសដែលប្រព្រឹត្តសមនឹងទទួលទោសស្រាល បែរត្រូវជាទទួលទោសធ្ងន់ធ្ងរទៅវិញ។

វត្ថុមាននៃអត្ថបទនេះ ផ្តោតលើតែបទឃាតកម្មគិតទុកជាមុន (deliberated killing/murder) ក្តោបនូវធាតុផ្សំ ដែលអាចទាញទៅពិចារណារកចំណុចដូច ឬខុសគ្នា នឹងបទល្មើសដទៃទៀត ដូចជា មនុស្សឃាតដោយចេតនា (Voluntary Manslaughter) ជាដើម។ ដូចសព្វដង អត្ថបទនេះនឹងចាប់ផ្តើមបរិយាយទូទៅ និងសង្ខេប អំពីប្រភេទនៃបទល្មើស មុននឹងពិនិត្យមើលធាតុផ្សំនៃបទល្មើស។ ក្នុងករណីមានភាពស្រពេចស្រពិល ឬមិនច្បាស់លាស់ នូវពាក្យពេចន៍ ស្ថានភាព ឬអត្ថន័យ យោបល់របស់អ្នកជំនាញផ្នែកច្បាប់ព្រហ្មទណ្ឌ ឬយុត្តិសាស្ត្ររបស់តុលាការបរទេស នឹងត្រូវបានយោងសម្រាប់ជាមូលដ្ឋានបន្ថែមក្នុងការឈ្វេងយល់ និងពិចារណាបន្ថែម។

អ្វីដែលត្រូវចាប់អារម្មណ៍ សូមកុំរំពឹងថា អត្ថបទដ៏ខ្លីនេះនឹងអាចឆ្លើយតប ឬដោះស្រាយគ្រប់សំណួរ ដែលអស់លោកអ្នកមាន។ អត្ថបទមួយនេះ គ្រាន់តែជាការចាប់ផ្តើម ដោយផ្តល់នូវសញ្ញាណជាក់លាក់មួយចំនួនប៉ុណ្ណោះ ទន្ទឹមនឹងនេះ អត្ថបទ ក៏មិនបានយោងដល់ការអនុវត្តកន្លងមក ឬការបកស្រាយ ឬយុត្តិសាស្ត្ររបស់តុលាការកម្ពុជាទេ។ វាគ្រាន់តែផ្តល់ជាមូលដ្ឋានសម្រាប់ពិចារណា និងសិក្សាបន្តតែប៉ុណ្ណោះ។

---

* លោក មាស បូរ៉ា ជាអ្នកស្រាវជ្រាវច្បាប់។

[24] មាត្រា ៤៣៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ កម្ពុជា។

# ២. ខ្លឹមសារ

## ២.១ បទប្បញ្ញត្តិច្បាប់

ក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តិ អំពីអំពើសម្លាប់មនុស្ស ក្នុងទម្រង់បទល្មើសមួយ ដោយក្នុងទម្រង់ជាបទល្មើសក្តោបរួម[25] មានស្ថានទម្ងន់[26] ឬជាបទល្មើសទោលតែឯង (stand alone)។ ករណីចុងក្រោយនេះ ដូចជាបទល្មើសឃាតកម្មក្នុងមាត្រា ១៩៩ (voluntary manslaughter) មនុស្សឃាតដោយអចេតនា (involuntary manslaughter) ក្នុងមាត្រា ២០៧ និងឃាតកម្មគិតទុកជាមុន (មាត្រា ២០០)។ បទល្មើសខ្លះ ភ្ជាប់ជាមួយនឹងស្ថានទម្ងន់ ទោសដោយកំណត់តាមរយៈមធ្យោបាយនៃការប្រព្រឹត្ត ឧទាហរណ៍ ការប្រើថ្នាំពុល (មាត្រា ២០១) ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ឧទាហរណ៍ះការធ្វើឲ្យជនរងគ្រោះពិការ (មាត្រា២០២) ស្ថានទម្ងន់ទោស ដោយសារគោលដៅ ឧទាហរណ៍ដូចជាការរារាំងមិនឲ្យសាក្សីផ្តល់ភស្តុតាង (មាត្រា ២០៣) ចារី (ប្រព្រឹត្តដោយអ្នករាជការសាធារណៈ) (មាត្រា ២០៤) ដោយប្រើទារុណកម្ម (មាត្រា ២០៥)។ ក្នុងករណីមានស្ថានទម្ងន់ អ្នកប្រព្រឹត្តនឹងអាចទទួលទោសពន្ធនាគារ តាមប្រភេទនៃស្ថានទម្ងន់ចន្លោះពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ។ បន្ថែមពីនេះ ជនល្មើសអាចនឹងត្រូវតុលាការប្រកាសទោសបន្ថែម ដែលមាន ៩ ប្រភេទ ដូចកំណត់ក្នុងមាត្រា ២០៦។

## ២.២. ធាតុផ្សំនៃបទល្មើស

មាត្រា២០០ បទឃាតកម្មគិតទុកជាមុនៈ ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការពួនស្ទាក់។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀន ទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ការពួនស្ទាក់គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

មុនចូលដល់ខ្លឹមសារចម្បង អត្ថបទ សូមបង្ហាញពីភាពខុសគ្នារវាងអំពើសម្លាប់មនុស្សខុសច្បាប់ទាំងបីប្រភេទនេះ។ បទឃាតកម្មគិតទុកជាមុន ឬឃាតកម្មដែលមានទោសធ្ងន់ជាងគេនេះ ដោយមានភ្ជាប់នឹងស្ថានទម្ងន់ ក៏ប៉ុន្តែឃាតកម្មធម្មតា ដែលគេហៅថាអំពើឃាតកម្មដោយមានចេតនាភ្លាមៗ (គឺគ្មានភ្ជាប់នឹងស្ថានទម្ងន់ទេ)។ ទាំងពីរនេះខុសគ្នានឹង បទមនុស្សឃាតដោយ

[25] ការសម្លាប់ជាផ្នែកមួយនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ មាត្រា ១៨៣ ២០០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ (១)។

[26] ដូចជាមាត្រា ២០២ ។(ស្ថានទម្ងន់ដោយសារជនរងគ្រោះ មានពិការភាព)

អចេតនា ដែលការសម្លាប់មនុស្សដោយសារទង្វើធ្វេសប្រហែសជាដើម។[27]

តាមទ្រឹស្តី មាត្រា២០០នេះ បង្ហាញពីធាតុផ្សំនីត្យានុកូលហើយ។ យើងនឹងពិនិត្យមើលជាបន្ត នូវប្រធាននៃបទល្មើស ជនរងគ្រោះ ដែលស្ថិតនៅក្នុងចំណោងជើងរង គឺធាតុផ្សំសម្ភារៈ និង ធាតុផ្សំអត្តនោម័ត។

ធាតុផ្សំសម្ភារៈ៖ សំដៅសកម្មភាព នៃការដកហូតជីវិតបុគ្គលណាមួយ ដែលជាជនរងគ្រោះដោយបុគ្គលណាម្នាក់ទៀត។ ជនរងគ្រោះជាមនុស្សដែលមានជីវិត។ ទោះបីមុនសម្លាប់ ជនរងគ្រោះនៅមានអាយុតែប៉ុន្មាននាទីក្តី[28] ឧទាហរណ៍ ការបាញ់សម្លាប់ ជាដើម។

ធាតុផ្សំអត្តនោម័តៈ ជនល្មើសមានចេតនាធ្វើឲ្យជនរងគ្រោះស្លាប់ ហើយចេតនានេះបង្ហាញ តាមរយៈ ការគិតទុកជាមុន ឬដោយការពួនស្ទាក់។ ការប្រើពាក្យ "ឬ" ក្នុងច្បាប់នេះ មានន័យថា ទោះជាអំពើនោះ ត្រូវប្រព្រឹត្តក្រោមស្ថានភាពណាមួយក៏ដោយក្នុងចំណោមស្ថានភាពទាំងពីរពោល គឺការគិតទុកជាមុន ឬ ការពួនស្ទាក់ នឹងត្រូវបានសន្មត់ថាជាបទឃាតកម្មគិតទុកជាមុន។ ពាក្យ "ការគិតទុកជាមុន" និងពាក្យ "ការពួនស្ទាក់" ត្រូវបានកំណត់និយមន័យក្នុងកថាខណ្ឌទី២ និងទី៣ នៃមាត្រា ២០០នៃក្រមព្រហ្មទណ្ឌ។ គន្ថីទី១ ស្តីអំពីបទប្បញ្ញត្តិទូទៅ ក៏បានផ្តល់និយមន័យនៃ "ការគិតទុកជាមុន ក្នុងមាត្រា ៧៨[29]" និង "ការពួនស្ទាក់ ក្នុងមាត្រា ៨២"ផងដែរ។ ប៉ុន្តែតាមទម្រង់នៃការតាក់តែងច្បាប់ និងគោលការណ៍ទូទៅ ការបកស្រាយក្នុងការអនុវត្ត ត្រូវតែយកអត្ថន័យដែលកំណត់ក្នុងបទប្បញ្ញត្តិដោយឡែក ហើយមានតែក្នុងករណីបទប្បញ្ញត្តិក្នុងគន្ថីដោយឡែកដែលមិនបានពន្យល់ ឬបកស្រាយប៉ុណ្ណោះ ទើបយកការបកស្រាយ ឬពន្យល់ក្នុងគន្ថីទី១ អំពីបទប្បញ្ញត្តិទូទៅយកមកអនុវត្ត។ ដូច្នេះអត្ថន័យនៃការគិតទុកជាមុន និងពួនស្ទាក់ គប្បីត្រូវបានបកស្រាយដោយផ្អែកលើអត្ថន័យក្នុងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។ ជាថ្មីម្តងទៀត ដោយសារ ប្រើពាក្យ "ឬ" វាមានត្រឹមតែការពួនស្ទាក់ ឬមានផែនការភ្លាមមុនប្រព្រឹត្ត បន្ថែមដោយការពួនស្ទាក់។ ទោះបីជាយ៉ាងនេះក្តី វាតម្រូវឲ្យមានពេលសមស្រប សម្រាប់សម្រេចសកម្មភាព។

នៅមានសំណួរជាច្រើនពាក់ព័ន្ធនឹងធាតុផ្សំទាំងពីរ៖ សំណួរមួយចំនួននឹងត្រូវបានស្រាយបំភ្លឺខាងក្រោម៖ ១. តើនៅពេលណាដែលគេចាត់ថាមានជីវិត ហើយនៅពេលណា គេចាត់ថាជនរង

---

[27] អត្ថបទស្រាវជ្រាវដោយឡែកពាក់ព័ន្ធបទល្មើសទាំងពីរប្រភេទចុងក្រោយ នឹងមានជាបន្តបន្ទាប់។

[28] មិនអាចសម្លាប់ខ្មោចទេ។

[29] អាដេម៉ាឡឺក្លែរ បានពន្យល់ថា ការគិតទុកជាមុន គឺជាសញ្ញាណដ៏មានសារៈសំខាន់មួយក្នុងការវាយតម្លៃ អំពីភាពធ្ងន់ធ្ងរនៃកំហុស ឱ្យកាន់តែពណ៌នាឱ្យបានច្បាស់លាស់ពីសកម្មភាពទាំងឡាយដែលបញ្ជាក់អំពី បំណងដែលមាននៅមុន" ពេលធ្វើសកម្មភាពប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈឹមណាមួយ ។"មាត្រា ៣៧ នៃក្រមវិវាទ អាដេម៉ាឡឺក្លែរ ក្រមកម្ពុជា ភាគ ២ ទំព័រ ៤៣១។

គ្រោះបានស្លាប់? ២. តើពាក្យគម្រោងមានន័យដូចម្តេច? និងអ្វីទៅជាបទប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន?

## ២.៣. យោបល់អ្នកជំនាញ យុត្តិសាស្ត្រ និងច្បាប់បរទេស

មុននឹងឆ្លើយសំណួរ អត្ថបទសូមធ្វើការកត់សំគាល់ លើចំណុចចំនួនបី៖ ទី ១. ពាក្យបកប្រែពីបារាំង ជាអង់គ្លេស គឺ Trap[30]។ តាមន័យធម្មតា ពាក្យនេះមានន័យថាជា "អន្ទាក់"។ ទោះបីជាយ៉ាងនេះក្តី ពាក្យនេះ ត្រូវបានប្រែជាភាសាខ្មែរ ថាការពួនស្ទាក់។[31] ទី២. ក្នុងក្រមព្រហ្មទណ្ឌបារាំងស្ថានទម្ងន់ពាក់ព័ន្ធអំពើសម្លាប់មនុស្សខុសច្បាប់ មានច្រើនប្រភេទ ក្នុងមាត្រាតែមួយ ក្នុងនោះក៏មានស្ថានទម្ងន់ ( ការគិតទុកជាមុន)[32] ក៏ប៉ុន្តែ ក្រមព្រហ្មទណ្ឌកម្ពុជាបានចែង មាត្រាដោយឡែកតែមួយគឺមាត្រា ២០០ និងទី៣. ប្រទេសខ្លះ បានប្រដូចមនុស្សឃាតគិតទុកជាមុនជាអំពើឃាតកម្មក្នុងកម្រិតទី១ (First Degree Murder) តួយ៉ាងប្រទេសកុំមុនឡូ។[33]

ក្រមព្រហ្មទណ្ឌកម្ពុជាបានកំណត់បន្ថែមថា ក្នុងអំឡុងពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ឬរំលោភសេពសន្ថវៈ ហើយក្នុងពេលប្រព្រឹត្ត ឬក្រោយពេលប្រព្រឹត្តបណ្តាលឱ្យជនរងគ្រោះស្លាប់គឺ ជាបទឃាតកម្មធ្ងន់ធ្ងរ ដោយត្រូវទទួលរងទោសដាក់ពន្ធនាគារអស់មួយជីវិត។[34] ក៏ប៉ុន្តែ សហរដ្ឋអាមេរិកចាត់ជាបទល្មើស ដោយឡែក គឺ Felony-Murder[35] ហើយប្រទេសអាឡឺម៉ង់មិនទទួលចាត់ទុកប្រភេទបទល្មើសដូចនេះទេ។[36]

ធាតុផ្សំសម្ភារៈ៖ មានការឯកភាពជាទូទៅថា អំពើឃាតកម្មគឺជា ទង្វើដកហូតជីវិតមនុស្ស។

---

[30] ដកស្រង់ក្នុង Catherine Elliot, France in p. 228 of Thomas Weigend, Germany in p. 277 of Kevin Jon Heller and Markus D. Dubber, Handbook of Comparative Criminal Law, 2011.

[31] បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២៣១ មាត្រា ,(១ត្រូវបាននិរាករណ៍ (ដោយក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ឆ្នាំ ២០០៧ ៦១១ មាត្រា))។ ដកស្រង់...

[32] មាត្រា ២២២ដ (៩) ៧-កស្រង់ក្នុង Catherine Elliot, France in p. 228 of Thomas Weigend, Germany in p. 277 of Kevin Jon Heller and Markus D. Dubber, លេខយោងទី៧ខាងលើ។

[33] Vivenne O'Connor and Colette Rausch, Model Codes for Post-Conflict Criminal Justice, Model Criminal Code, 2007, p. 220។

[34] ក្រមព្រហ្មទណ្ឌមាត្រា ២៤៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

[35] Paul H. Robinson, United States in p. 589 of Kevin Jon Heller and Markus D. Dubber, លេខយោងទី៧ខាងលើ។ អ្នកប្រព្រឹត្ត មានចេតនារំលោភ ដូចនេះ គេអាចទាញចេញពីនេះ ថាគាត់មានចេតនាសម្លាប់ជនរងគ្រោះ (constructive mens rea), NA Morgan, Criminal Law in Singapore and Malaysia, 1989, p.426។

[36] Thomas Weigend, Germany in p. 277 and Australia by Simon Bronitt, p. 79 of Kevin Jon Heller and Markus D. Dubber, លេខយោងទី៧ខាងលើ។

នេះមានន័យថា ជនរងគ្រោះ ត្រូវតែជាមនុស្សមានជីវិតមុនពេលប្រព្រឹត្ត ទោះបីក្នុងរយៈពេលប៉ុន្មាននាទីចុងក្រោយក្តី។[37] តើមនុស្សត្រូវបានចាត់ទុកថាស្លាប់នាពេលណា និងចាប់ផ្តើមជីវិតនាពេលណា? ជីវិតចាប់ផ្តើមពេលកើតពីម្តាយ ហើយទារកអាចរស់ឯករាជ្យពីម្តាយ[38] និងបញ្ចប់ នៅពេលដែលខួរក្បាល លែងដំណើរការ (death of brain)។[39] កម្ពុជាមានច្បាប់រំលូតកូន ដែលអាចអនុញ្ញាតឲ្យពេទ្យជំនាញយកគភ៌ចេញ ដែលបណ្តាលឲ្យស្លាប់ទារកនោះ។ គេអាចបកស្រាយថា គភ៌មិនទាន់ត្រូវបានចាត់ថាជាមនុស្សមានជីវិតក្នុងន័យ ជាកម្មវត្ថុនៃបទល្មើសមនុស្សឃាតទេ។ ដើម្បីជម្រះមន្ទិល ប្រទេសខ្លះចែងអំពីបទសម្លាប់កុមារ ជាពិសេសដោយម្តាយក្រោយពីផ្តល់កំណើត។[40]

ការគិតទុកជាមុន បង្ហាញពីការរៀបចំជាមុននូវសកម្មភាពមួយចំនួន ក្នុងរយៈពេលមួយ។ ការចុះកិច្ចសន្យាដើម្បីសម្លាប់ ជាឧទាហរណ៍មួយនៃសកម្មភាពនេះ។[41] វាជាការគ្រោងផែនការរៀបចំ ដោយប្រយ័ត្នប្រយែង អំពីសកម្មភាព ផលវិបាកកើតមាន។ វាមិនចាំបាច់ស្មុគស្មាញទេ។ "ខ្ញុំគិតថា ក្នុងក្រមពាក្យ "ផែនការ" ជាការរៀបចំ ឬគម្រោង ដែលត្រូវបានធ្វើឡើងដោយហ្មត់ចត់ជាមួយផលវិបាក ត្រូវបានពិចារណា និងថ្លឹងថ្លែង។ ក៏ប៉ុន្តែ នេះមិនមានន័យថា ចាំបាច់ទាល់តែស្មុគស្មាញទេ។ ផែនការអាចសាមញ្ញ ហើយប្រហែលជា កាន់តែសាមញ្ញ កាន់តែស្រួលរៀបចំ"។[42]

ធាតុអត្តនោម័តៈ តាមខ្លឹមសារខាងលើ តាមរយៈផែនការ វាបង្ហាញពីចេតនា នៃជនល្មើសចង់ឲ្យជនរងគ្រោះត្រូវតែស្លាប់ ដោយសារ ផែនការត្រូវបានរៀបចំជាមុន។

ចេតនា បានបង្ហាញតាមរយៈថា ជនល្មើស មានបំណងឲ្យមានរបួសធ្ងន់ធ្ងរ (fatal injury) និងបានដឹងថារបួសនោះ នឹងធ្វើឲ្យជនរងគ្រោះស្លាប់។ ជនល្មើសបាន បាញ់ទៅលើគ្រែដេក ស្មានថាមនុស្សមុខសញ្ញា ដេកនៅទីនេះតែបែរជាគ្រែទទេ (empty bed)។ ជនល្មើសបានបាញ់លើជនរង

---

[37] កើត រិទ្ធ ឯកសារជំនួយសម្រាប់ការសិក្សាស្រាវជ្រាវ ស្តីពីបទមនុស្សឃាត ទំ.២) ឯកសារមាននៅជាមួយ អ្នកនិពន្ធនេះ

[38] NA Morgan, លេខយោងទី១២ p. 403។

[39] NA Morgan, ដូចខាងលើ p. 403។ Michael Bohlander, Principles of German Criminal Law, 2009, p. 182; Jonathan Burchell, South Africa in p. 475 of Kevin Jon Heller and Markus D. Dbber, លេខយោងទី ៧ខាងលើ។

[40] Filicide or Infanticide, For example in England and Wales have Infanticide Acts, https://www.ncbi.nlm.nih.gov/pmc/articles/PMC2174580/

[41] *I think that in the Code "planned" is to be assigned, I think, its natural meaning of a calculated scheme or design which have been carefully thought out, and the nature and consequence of which have been considered and weighed. But that does not mean, of course, to say that the plan need be a complicated one. It may be a very simple one, and the simpler it is perhaps the easier it is it formulate*, John L. Gibson, Canadian Criminal Code Offences, 1993, p.31-24។

[42] *R. v. Widdifield* (1961), 6 Cr. L.Q. 152 at 153, Quoted in John L. Gibson, លេខយោងទី១៨ ខាងលើ, p.31-24។

គ្រោះ តែគ្រាប់កាំភ្លើងស្ទុយ ឬបាញ់លើសាកសព ដែលស្លាប់រួចទៅហើយ។ ជាចុងក្រោយ មានករណីមួយដែលជនល្មើសបានដាក់ភ្លើងក្បែរពូករួចដេក។ ក្រោយមកគាត់មើល និងដឹងថាអាចនាំឲ្យឆេះដែលបង្កឲ្យមនុស្សជរាម្នាក់ទីនោះបានស្លាប់។ ទាំងអស់នេះ សុទ្ធតែបង្ហាញពីចេតនា ចង់ឲ្យជនរងគ្រោះស្លាប់ ទោះបីជាអង្គហេតុអាចចាត់ថា ជាបទឃាតកម្មគិតទុកជាមុន ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសនេះ។[43] អង្គហេតុចុងក្រោយ នាំឲ្យមានការសន្និដ្ឋានថាមានចេតនា ផ្អែកលើមូលដ្ឋានថា ជនល្មើសគាត់ជាអ្នកបង្ក និងមានកាតព្វកិច្ច រារាំងហានីភ័យ (ភ្លើងឆេះបណ្ដាលឲ្យស្លាប់) តែគាត់មិនរារាំង។

វានៅមានភាពស្មុគស្មាញជាច្រើនទៀត ក្នុងការអនុវត្ត និងទាញសន្និដ្ឋានថា វាជាឃាតកម្មគិតទុកជាមុន ឬមិនមែន ដោយសារតែមានអង្គហេតុផ្សេងៗជាច្រើនទៀតខុសៗគ្នា។ ឧទាហរណ៍ ប្ដីបានវាយប្រពន្ធចំក្បាល ច្របាច់កងនាងឲ្យស្លាប់។ គាត់ជឿថា នាងបានស្លាប់ទៅហើយ ហើយបានយកនាងទៅចងក ដើម្បីភូតថា ជាករណីអត្តឃាត។[44]

ក្នុងអង្គហេតុនេះ វាមានសកម្មភាពជាច្រើនជាកញ្ចប់ ដើម្បីសម្រេចបានការសម្លាប់មួយ។ ភស្តុតាង បានបង្ហាញថា ត្រឹមតែវាយក្បាល និងសន្លប់ នាងមិនទាន់ស្លាប់ទេ។ ការស្លាប់នេះដោយសារការថប់ដង្ហើម ដោយសារចងក។ នេះបង្ហាញថា សកម្មភាព (ធាតុសម្ភារៈ) មិនកើតស្របគ្នានឹង (coincidence) ចេតនាឲ្យស្លាប់ភ្លាមទេ។ ប្រសិនការប្រកាន់ជំហរដូចនេះ វាមិនមែនជាឃាតកម្មគិតទុកជាមុនទេ។ ផ្សេងពីនេះ វាជាឃាតកម្មគិតទុកជាមុន ដោយសារគេពិចារណា មើលចេតនា និងសកម្មភាព។ គាត់វាយហើយ ចងក ដើម្បីគេជឿថា ជាករណីអត្តឃាត។ ទង្វើនេះ គាត់ចង់ឲ្យប្រពន្ធស្លាប់។ ទាញចេញពីនេះ ប្រសិនដឹងថា នាងមិនទាន់ស្លាប់ គាត់នឹងធ្វើសកម្មភាពអ្វីមួយទៀត ដើម្បីឲ្យនាងស្លាប់ ដូចផែនការ និងលទ្ធផលដែលរំពឹងទុក។

## ៣. សង្ខេប

ឃាតកម្មគិតទុកជាមុន ជាការសម្លាប់មនុស្សដោយចេតនា បង្ហាញតាមរយៈគម្រោង ឬផែនការ ដើម្បីសម្រេចតាមការរំពឹងទុក។ ជនរងគ្រោះត្រូវតែជាមនុស្សមានជីវិត ទោះបីប៉ុន្មាននាទីមុខសកម្មភាពសម្លាប់កើតឡើងក្ដី។ យុត្តិសាស្ត្របានបង្ហាញថា ពេលណាដែលជីវិតត្រូវបានចាត់ថាបញ្ចប់នោះគឺការឈប់ដំណើរការនៃខួរក្បាល។ នៅមានបញ្ហាស្មុគស្មាញក្នុងការបែងចែកមនុស្សឃាត និងក៏ប៉ុនប៉ងប្រព្រឹត្តមនុស្ស ដែលអ្នកសិក្សាក្រោយៗ គួរបន្តស្រាវជ្រាវ តាមរយៈការលើកអង្គហេតុជាក់ស្ដែង ជាឧទាហរណ៍ ដើម្បីបំភ្លឺ Gray Zone។

43 យុត្តិសាស្ត្របារាំង ចាជាការប៉ុនប៉ង ,Catherine Elliott, French Criminal Law, 2001, p. 149។

44 NA Morgan, លេខយោងទី ១២ ខាងលើ, p. 431.

# លំហូរនីតិវិធីព្រហ្មទណ្ឌ
# នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

ដោយលោក អន សម័យ*

## សេចក្តីផ្តើម

នីតិវិធីព្រហ្មទណ្ឌគឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់វិជ្ជាជីវៈមេធាវី ក្នុងការការពារសិទ្ធិ ជូនជនរងគ្រោះ ក៏ដូចជាជនជាប់ចោទ នៅក្នុងរឿងក្តីព្រហ្មទណ្ឌដូចគ្នានេះដែរក្នុងឆ្នាំ២០២០នេះ ក្រសួងយុត្តិធម៌បាននឹងកំពុងអនុវត្តនូវវិធានការដោះស្រាយបញ្ហាកកស្ទះសំណុំរឿង នៅតាមបណ្តាសាលាដំបូងខេត្ត-រាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ក្នុងគោលបំណងជម្រុញវិស័យយុត្តិធម៌នៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។ ដូច្នេះហើយដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ ការសិក្សាស្រាវជ្រាវទាក់ទងនឹងលំហូរនីតិវិធីព្រហ្មទណ្ឌពិតជាមានសារសំខាន់ ក្នុងការជួយសម្រួលដល់អ្នកស្រាវជ្រាវ ជាពិសេសចំពោះមេធាវីដែលស្ថិតក្នុងកម្មសិក្សា។

បើសិក្សាទៅលើលំហូរនីតិវិធីព្រហ្មទណ្ឌនេះយើងសង្កេតឃើញមានការបែងចែកលំហូរនីតិវិធីព្រហ្មទណ្ឌជាបួនដំណាក់កាលធំៗគឺ៖ទី១. ដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ ទី២. ដំណាក់កាលព្រះរាជអាជ្ញា ទី៣. ដំណាក់កាលចៅក្រមស៊ើបសួរ និងទី៤. ដំណាក់កាលជំនុំ ជម្រះ។

នៅក្នុងស្មារតីនៃការរៀបចំសរសេរអត្ថបទស្តីអំពី **លំហូរនីតិវិធីព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌** យើងសូមលើកយកតែដំណាក់កាលទីមួយគឺដំណាក់កាល មន្ត្រីនគរបាល យុត្តិធម៌យកមក អត្ថាធិប្បាយតែប៉ុណ្ណោះ ដែលក្នុងនោះការដាក់ពាក្យបណ្តឹង ស្ថិតក្នុង (I) និងដំណើរការនីតិវិធីរបស់មន្ត្រី នគរបាល យុត្តិធម៌ស្ថិតក្នុង (II) ។[1]

## I. បណ្តឹង

### *និយមន័យ*

បណ្តឹងគឺជាអំណាចមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គលឬនីតិបុគ្គលដែលប្តឹងទៅ

---

* អ្នកនិពន្ធបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិសហប្រតិបត្តិការសេដ្ឋកិច្ច និងធុរៈកិច្ចអន្តរជាតិជាភាសាបារាំងដែលសហប្រតិបត្តិការរវាងសាកលវិទ្យាល័យជាតិវៀតណាម និងសាកលវិទ្យាល័យបកដូប្រទេសបារាំង។ លោកក៏បានទទួលសញ្ញាបត្រ ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបារាំងដែលសហប្រតិបត្តិការរវាងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ លីយ៉ុង ២ ប្រទេសបារាំង។

[1] បទបញ្ញត្តិស្តីពី នគរបាលយុត្តិធម៌នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

តុលាការដើម្បីទាមទារអោយមានការគោរពសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់បុគ្គលនោះ។ បណ្តឹងនេះត្រូវ បានបែងចែកជាពីរគឺ ទី១ បណ្តឹងទាមទារ និងទី២ បណ្តឹងបរិហារៈ

ក. បណ្តឹងទាមទារ

*១.និយមន័យ*

*បណ្តឹងទាមទារ គឺជាការដាក់ពាក្យបណ្តឹងដោយជនរងគ្រោះ ដែលជននោះបាន ប្រកាសថាខ្លួនជាជនរងគ្រោះនៃបទល្មើស។*[2]

*២.បុគ្គលដែលអាចប្តឹង*

នៅក្នុងរឿងព្រហ្មទណ្ឌបណ្តឹងទាមទារ ត្រូវបានដាក់ពាក្យប្តឹងដោយជនរងគ្រោះ ប៉ុន្តែឧទារណ៍ថា ជនរងគ្រោះនៃបទល្មើសជាអនីតិជន ឬជនស្ថិតនៅក្រោមរបបអាណាព្យាបាល ទូទៅឬជនស្ថិតក្រោមហិតូបត្ថម្ភគឺអ្នកតំណាងស្របច្បាប់របស់ជននោះអាចប្តឹងជំនួសបាន។[3]ក្នុងនោះដែរ ប្រសិនបើ ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវប្តឹង ដោយសិទ្ធិវន្តរបស់ជនរងគ្រោះ។[4] តែការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវតែធ្វើឡើងក្នុងនាមដើម្បីតែផលប្រយោជន៍របស់ជនរងគ្រោះតែប៉ុណ្ណោះដែលការតាំងខ្លួននេះអាចធ្វើនៅពេលណាដ៏បានដែរ ប្រសិនបើចៅក្រមពុំទាន់បានសម្រេចលើអង្គសេចក្តីនោះទេ។

លើសពីនេះទៅទៀត សមាគមក៏អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដែរ ដូចជាសមាគមប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំង នឹងកុមារ[5] សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្ម ផ្លូវភេទ[6] និង សមាគមប្រយុទប្រឆាំងនឹងការប្រកាន់ពូជសាន៍ និងការរើសអើង[7]។ ក៏ប៉ុន្តែបណ្តឹងដែលធ្វើដោយសមាគមទាំងនេះ អាចទទួលយកបានលុះត្រាតែមានភស្តុតាង បញ្ជាក់ថា សមាគមបានទទួលការយល់ព្រមអំពីសិទ្ធិពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ នៃជនរងគ្រោះ។[8]

[2] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[3] មាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[4] មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[5] មាត្រា១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[6] មាត្រា ១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[7] មាត្រា ១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[8] មាត្រា ២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### *៣.ការដាក់ពាក្យបណ្ដឹង*

នៅក្នុងរឿងព្រហ្មទណ្ឌ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ ឬសិទ្ធិវ័ន្តរបស់ជនរង គ្រោះ ឬសមាគមពាក់ព័ន្ធអាចប្ដឹងទៅមន្ត្រីនគរបាលយុត្តិធម៌[9] និងអយ្យការដែលទទួលចំណាត់ការលើពាក្យបណ្ដឹងដែលខ្លួនទទួលបានដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក[10]។

## ខ. បណ្ដឹងបរិហារ

### *១.និយមន័យ*

បណ្ដឹងបរិហារ គឺជាបណ្ដឹងមួយដែលបរិហាពីបទល្មើស។ ដូច្នេះនៅពេលដែលមានបទល្មើសណាមួយកើតឡើង ហើយប៉ះពាល់ទៅដល់ផលប្រយោជន៍សារធារណៈ ឬឯកជន គឺតតីជនមានសិទ្ធិក្នុងការឈឺឆ្អាល ទៅនឹងអំពើនោះពោលគឺជននោះអាចប្ដឹងបរិហារអំពីបទល្មើសនោះបាន។

### *២.ការដាក់ពាក្យបណ្ដឹង*

បណ្ដឹងបរិហារ អាចធ្វើឡើងដោយបុគ្គលទូទៅឬប្រជាជនទូទៅ ឧបមាថាយើងបានឃើញមនុស្សស្លាប់ ហើយយើងមិនបានដឹងថាអ្នកណាសម្លាប់នោះដែរ ដូច្នេះជាគោលការណ៍យើងជាអ្នកបានឃើញមនុស្សស្លាប់នោះ ក៏មានសិទ្ធិប្ដឹងទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ។ ប៉ុន្តែបណ្ដឹងរបស់យើងនេះគ្រាន់តែជាសេចក្ដីរាយការណ៍អំពីបទល្មើសតែប៉ុណ្ណោះ។

បន្ទាប់ពីមានសេចក្ដីរាយការណ៍អំពីបទល្មើសដូចខាងលើ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹងនិងពាក្យបរិហារដែលខ្លួនបានទទួលផ្ទាល់ក្នុងនេះដែរ ព្រះរាជអាជ្ញាក៏អាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬអាចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។[11]

លើសពីនេះទៅទៀតអាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលស្ថិតនៅក្នុងកំឡុងពេលបំពេញមុខងាររបស់ខ្លួន ហើយបានដឹងអំពើជាបទឧក្រិដ្ឋ ឬមជ្ឈិម គឺត្រូវមានកាតព្វកិច្ចធ្វើបណ្ដឹងបរិហារចំពោះបទឧក្រិដ្ឋនោះ ដោយជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ហើយការរាយការណ៍ព័ត៌មាននេះ ត្រូវមានភ្ជាប់ជាមួយនូវកំណត់ហេតុ លិខិត និងវត្ថុតាង

[9] មាត្រា ៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[10] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[11] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ទាំងអស់ដែលទាក់ទងនឹងបទល្មើស វាលែងតែអាចកំបាំងខាងវិជ្ជាជីវៈដែលច្បាប់បានចែងយ៉ាងជាក់លាក់ នោះទេ។[12]

ក្នុងនេះដែររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង ចំពោះបទល្មើសដែលខ្លួនបានដឹង ដែលក្នុងនោះ រដ្ឋមន្ត្រីក្រសួងយុត្តិ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់ចូលក្នុងសំណុំរឿង ដើម្បីឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋាន។

### *៣.ផលវិបាកនៃការប្តឹង និងការមិនប្តឹងបរិហារ*

យើងបានដឹងហើយថា បណ្តឹងបរិហារគឺជាបណ្តឹងដែលបរិហារទៅលើបទល្មើស ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ បានទទួលព័ត៌មានដែលទាក់ទងទៅនឹងអំពើល្មើស និងដើម្បីស្វែងរកនូវយុត្តិធម៌ជូនជនរងគ្រោះ ក៏ប៉ុន្តែដើម្បីធានាឱ្យបាននូវព័ត៌មានជាក់ច្បាស់ដែលឈានទៅដល់ការរកយុត្តិធម៌ជូនជនរងគ្រោះបានច្បាប់ក៏ បានបញ្ញត្តិនូវលក្ខខ័ណ្ឌទណ្ឌកម្មមួយចំនួនចំពោះបុគ្គលដែលពាក់ព័ន្ធដូច ខាងក្រោម៖

### ក.បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ

បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ គឺមានន័យថាជាការប្តឹងបរិហារ មួយដល់អាជ្ញាធរតុលាការអំពីបទល្មើស ក៏ប៉ុន្តែការប្តឹងនេះនាំឱ្យកិច្ចការស្រាវជ្រាវរបស់សមត្ថកិច្ចពាក់ព័ន្ធប្រែជាឥតប្រយោជន៍ ដូច្នេះជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ១លាន រៀល។[13] ឧបមាថាបុគ្គលម្នាក់ គាត់ប្តឹងទៅ សមត្ថកិច្ច ដោយធាតុពិតគឺពុំមានអង្គហេតុ បទល្មើសសោះឡើយ បន្ទាប់មកសមត្ថកិច្ចខិតខំ ស្រាវជ្រាវលើកិច្ចការស៊ើបអង្កេត តែទីបំផុតទើបដឹងថាការប្តឹងគឺជាការភូតកុហក ដូច្នេះបុគ្គលនោះត្រូវមានទណ្ឌកម្មដូច បានរៀបរាប់ខាងលើ។

### ខ. បទមិនប្តឹងបរិហារបទឧក្រិដ្ឋ ឬមជ្ឈិមដោយអ្នករាជការសាធារណៈ

ការប្តឹងបរិហារបទល្មើសព្រហ្មទណ្ឌគឺ ជាកាតព្វកិច្ចមួយដ៏សំខាន់សម្រាប់ផ្តល់ព័ត៌មាន ដល់សមត្ថកិច្ចពាក់ព័ន្ធដែលអាចឈានទៅរកការរកយុត្តិធម៌ដល់ជនរងគ្រោះ ក៏ប៉ុន្តែប្រសិនបើបុគ្គលណាមួយបានដឹងហើយថា មានបទល្មើសពិតមែនតែខ្លួនបែរជាមិនប្តឹងទៅវិញជននោះ នឹងត្រូវផ្តន្ទា

---

12 មាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

13 មាត្រា ៥២៤ នៃក្រមព្រហ្មទណ្ឌ

ទោសដូចគ្នាផងដែរ។ ជាឧទាហរណ៍ អ្នករាជការសារធារណៈ ដែលបានដឹងអំពីអំពើល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិម តែខ្លួនបែរជាបោះចោល ឬមិនបានប្ដឹងបរិហារដល់អាជ្ញាធរ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចនៅ កំឡុងពេលដែលខ្លួនស្ថិតនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសការបំពេញមុខងាររបស់ខ្លួន នោះបុគ្គលនោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លាន រៀល ទៅ៦លានរៀល។[14]

### គ. បទមិនប្ដឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង

ដូចគ្នានេះដែរ កាលណាបុគ្គលទូទៅ ឬប្រជាជនដែលបានពីបទឧក្រិដ្ឋ ដែលអាចនឹង បង្ការ ឬបន្ថយអានុភាពរបស់បលល្មើសបាន តែខ្លួនបែរជាមិនប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរតុលាការ ដូច្នេះបុគ្គលនោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀលទៅ២លានរៀល។ ក៏បុន្តែក៏មានករណីលើកលែងផងដែរ ចំពោះបុគ្គលមួយចំនួនដែលមិនបានប្ដឹងបរិហារដូចជា៖

- បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ។
- សហព័ទ្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ
- បុគ្គលដែលច្បាប់តម្រូវឱ្យរក្សាអាថ៌កំបាំងនៃវិជ្ជាជីវៈ។[15]

### ឃ. បទមិនប្ដឹងបរិហារការធ្វើបាបអនីតិជន

សព្វថ្ងៃអនីតិជនត្រូវបានការពារយ៉ាងយកចិត្តទុកដាក់ពីស្ថាប័នផ្សេងៗ ជាពិសេសគឺផ្ដោតសំខាន់ទៅ លើការការពារទៅលើរូបរាង្គកាយអនីតិជន និងការបៀតបៀនផ្លូវភេទលើអនីតិជន ដូច្នេះ ប្រសិនបើបុគ្គលណាមួយដែលទាក់ទងទៅនឹងការធ្វើបាបអនីតិជន ឬការបៀតបៀនផ្លូវភេទ អនីតិជនក្រោម១៥ឆ្នាំ ហើយបែរជាមិនប្ដឹងទៅអាជ្ញាធរតុលាការ ឬសមត្ថកិច្ចពាក់ព័ន្ធទេ បុគ្គលនោះនឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារចាប់ពី១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល។[16]

### ង. បទប្ដឹងបរិហារបង្កាច់កេរ្តិ៍

ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្ដឹងបរិហារអំពីអំពើដែលគេដឹងថា មិនពិតហើយ

[14] មាត្រា ៥២៨ នៃក្រមព្រហ្មទណ្ឌ

[15] មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌ

[16] មាត្រា ៥៣០ នៃក្រមព្រហ្មទណ្ឌ

នាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ។ នៅក្នុងនេះដែរ ប្រសិនបើបុគ្គលណាមួយបានប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការ ដូចជា ចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ បុគ្គលដែលមានអំណាចប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច នោះជននោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សេនរៀល ទៅ២លានរៀល។[17]

ក្រោយពីយើងបានស្វែងយល់អំពី បណ្ដឹងទាំងពីរខាងលើយើងសូមបន្តធ្វើការបង្ហាញ ពីនីតិវិធីបន្ទាប់ ក្រោយមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យបណ្ដឹង ថាតើមានដំណាក់កាលអ្វីខ្លះដើម្បីស្រាវជ្រាវបទល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។

## II. ដំណើរការនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌

ដើម្បីឈានដល់ការសិក្សាអំពីនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិបាន យើងសូមបង្ហាញថាតើនណាទៅជាមន្ត្រីនគរបាលយុត្តិធម៌? នគរបាលយុត្តិធម៌ សំដៅដល់មន្ត្រីរាជការសាធារណៈដែលមានមុខងាពិសេស ក្នុងការពារ និងថែរក្សាសណ្ដាប់ធ្នាប់សាធារណៈក្នុងសង្គមដោយផ្ដោតសំខាន់ទៅលើការ ចូលរួមពង្រឹងផ្នែកយុត្តិធម៌ និងជាជំនួយរបស់អំណាចតុលាការ។ យើងឃើញសមាសភាពនគរបាលយុត្តិធម៌ដូចជា៖

១. មន្ត្រីនគរបាលយុត្តិធម៌៖ មន្ត្រីនគរបាលយុត្តិធម៌សំដៅលើជនដែលត្រូវបាន ទទួលស្គាល់ដោយច្បាប់ដែលជាមន្ត្រីនគរបាល ឬនាយទាហាននៃកងរាជអាវុធហត្ថចាប់ពីអនុសេនីយ៍ត្រីឡើងទៅនិងមន្ត្រីសាធារណៈ ដទៃទៀត ដូចជា៖ មេឃុំ ចៅសង្កាត់ និងមន្ត្រី ស្ថាប័នមួយចំនួនទៀត (មន្ត្រីគយ មន្ត្រីជលផលជាអាទិ៍)។ ដើម្បីទទួលបានសម្បទាជា មន្ត្រី នគរបាលយុត្តិធម៌បាន សាមីជនត្រូវបំពេញគុណសម្បត្តិ០២(ពីរ) គឺ៖ តាមរយៈការប្រឡង និង តាមរយៈឋានន្តរស័ក្ក និងមុខងារ។

២.ភ្នាក់ងារនគរបាលយុត្តិធម៌៖សំដៅលើជនដែលគ្មានគុណសម្បត្តិជា មន្ត្រី នគរបាលយុត្តិធម៌ដូចជា៖

ទី១. នាយនគរបាល និងនាយនគរបាលរង

ទី២. ភ្នាក់ងារនគរបាលជាតិផ្សេងទៀត

ទី៣. នាយទាហាននៃកងរាជអាវុធហត្ថ

[17] មាត្រា ៣១១ នៃក្រមព្រហ្មទណ្ឌ

ទី៤. យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ។ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថនៅចំពោះមុខសាលាដំបូងរាជធានី-ខេត្ត។

៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាច ឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងសមត្ថកិច្ចរបស់ខ្លួន។[18]

បន្ទាប់ពីយើងបានដឹងអំពីនិយមន័យ និងតួអង្គរបស់មន្ត្រីនគរបាលយុត្តិធម៌ យើងសូមលើកយកនូវដំណាក់ធំៗចំនួន៣ដែលស្ថិតក្នុងកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌គឺ៖

- ទី១, ការស៊ើបអង្កេតករណីជាក់ស្តែង
- ទី២, ការស៊ើបអង្កេតបឋម
- ទី៣, ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខ័ណ្ឌនៃការស៊ើប អង្កេត

## ១) ការស៊ើបអង្កេតករណីជាក់ស្តែង

### ក១.បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

នៅក្នុងរឿងព្រហ្មទណ្ឌយើងមានបទល្មើសជាក់ស្តែងពីរគឺ បទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ ស្តែង។

ដូចនេះតើអ្វីទៅជាបទល្មើសជាក់ស្តែង? បទល្មើសជាក់ស្តែងគឺជាបទល្មើសទាំងឡាយណាដែលកំពុងតែប្រព្រឹត្ត ឬដែលទើបប្រព្រឹត្តរួច។ ក្នុងនោះដែរត្រូវចាត់ទុកថាជាបទល្មើសជាក់ស្តែងផងដែរ កាលណានៅ ក្រោយពេលមានបទល្មើសរួចបន្តិចមក៖

- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកីង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស ឬបានចូលរួមប្រព្រឹត្តបទល្មើស។[19]

ក្នុងនេះដែរ ប្រសិនបើបទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ប្រសិនបើគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ក៏អាចចាត់

[18] មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[19] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងបានដែរ។ ក្នុងករណីនេះភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ ជូនមន្ត្រីនគរបាលយុត្តិធម៌។[20]

### ខ១.វិធានការស្រាវជ្រាវ

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌មានវិធានការដូចជា៖

#### *១. ការរក្សាភស្តុតាង*

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា និងចុះទៅកន្លែងកើតហេតុដើម្បីពិនិត្យបទល្មើស ដោយធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ និងឃាត់ខ្លួនបុគ្គលគ្រប់រូប កុំឱ្យចេញពីកន្លែងកើតហេតុរហូតដល់ពេលបញ្ចប់ កិច្ចប្រតិបត្តិរបស់ខ្លួន។[21] ក្នុងនេះដែរព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងកើតហេតុ និងធ្វើការដឹកនាំការស៊ើបអង្កេត ប្រសិនបើខ្លួនយល់ឃើញថាមានភាពចាំបាច់ ឬម្យ៉ាងទៀតព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយតាមរយៈផ្ទាល់មាត់ប្រសិនបើក្នុងករណីបន្ទាន់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសន៍ក្នុងលិខិតស៊ើបអង្កេត។[22] ពេលនោះដែរមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការ ពិនិត្យរបស់ខ្លួន។ [23]

#### **២. ការឆែកឆេរ**

ដើម្បីស្វែងរកភស្តុតាង ឬតម្រុយបន្ថែមទៀតមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ ដែលការឆែក ឆេរនេះត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីតាមមធ្យោបាយណាមួយក៏ដោយ។ ក្នុងការឆែកឆេរនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើប្រតិបត្តិការនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើ ឡើងនៅចំពោះមុខសាក្សីពីរនាក់ ហើយ សាក្សីនេះផងដែរ ត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ដែល សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។[24]

គួកត់សម្គាល់ផងដែរថា ការឆែកឆេរក៏មានលក្ខខណ្ឌហាមឃាត់មួយចំនួនផងដែរដូចជា៖

[20] មាត្រា ៨៨ នៃក្រមនីតិវិធីប្រហ្មទណ្ឌ

[21] មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[22] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[23] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[24] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក. មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្ដើមធ្វើការឆែកឆេរមុនម៉ោង៦ និងក្រោយម៉ោង១៨ បានឡើយ លើកលែងតែករណីៈ

- បទល្មើសជាក់ស្ដែង
- ការចាត់ទុកដូចជាបទល្មើសជាក់ស្ដែង
- មានការស្រែកឱ្យគេជួយពីក្នុងទីកន្លែងណាមួយ
- ការឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន
- ការឆែកឆេរគ្រប់ទីកន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿង ញៀនជា ឧទាហរណ៍ស្រាប់ ដែលយើងបានឃើញនាពេលកន្លងមក គឺមានការឆែក ឆេរនៅក្នុង ក្លិបកំសាន្តជា បន្តបន្ទាប់ហើយការឆែកឆេរសុទ្ធតែធ្វើឡើងនាពេលយប់។

ខ.ការឆែកឆេរនៅក្នុងការិយាល័យមេធាវី

ត្រូវបានហាមឃាត់សម្រាប់មន្ត្រីនគរបាលយុត្តិធម៌ វាលែងតែព្រះរាជអាជ្ញាឬចៅក្រមស៊ើបសួរ តែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរបាន ហើយការឆែកឆេរត្រូវធ្វើនៅចំពោះមុខប្រធានគណៈ មេធាវី ឬប្រតិភូរបស់ប្រធាន គណៈមេធាវី ឬមេធាវីសាមីខ្លួន។

គ. ការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហ គ្រាសសារព័ត៌មានសោតទស្សន៍ អាចធ្វើទៅបានតែចំពោះមុខ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។[25]

បន្ទាប់ពីបានឆែកឆេររួចហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើ វត្ថុតាងដែលចាប់បាន ដែលវត្ថុតាងត្រូវបង្ហាញដល់អ្នកកាន់ទីកន្លែង ឬដល់សាក្សីឱ្យបាន ឃើញដោយ តម្រូវឱ្យមានការធ្វើកំណត់ហេតុ ហើយកំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬផ្ដិតមេដៃដោយអ្នកកាន់ កាប់ទីកន្លែង ឬសាក្សី។[26]

### ៣. ការស្ដាប់ចម្លើយ

ដើម្បីងាយស្រួលនៅក្នុងការស្ដាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌អាចហៅ ឬនាំខ្លួន បុគ្គលគ្រប់រូបដែល សង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស មកកាន់អង្គភាពរបស់ខ្លួនបាន ដោយរាល់ការ ស្ដាប់ចម្លើយត្រូវមានកំណត់ហេតុ ប្រសិនបើក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចរកជំនួយ

[25] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[2626] មាត្រា ៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ពីអ្នកបកប្រែ ដែលបានស្បថថា និយាយតែការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុជូនភាគីពាក់ព័ន្ធ ហើយកំណត់ហេតុនេះត្រូវតែចុះហត្ថលេខា ឬផ្ដិតមេដៃរបស់បុគ្គលដែលបានឆ្លើយ ប្រសិនបើបុគ្គលនោះមិនព្រមផ្ដិត ឬចុះហត្ថលេខាទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចុះក្នុងនិទ្ទេស កំណត់ ហេតុ។[27]

លើសពីនេះផងដែរ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្ដាប់ចម្លើយបុគ្គលគ្រប់រូប ក៏ប៉ុន្តែប្រសិន បើបុគ្គលនោះរឹងទទឹងមិនព្រមសហការជាមួយខ្លួនទេ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចនឹងចេញបញ្ជាឱ្យចូលខ្លួនបាន ហើយបទបញ្ជានេះ មានអានុភាពឱ្យមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គល នោះឱ្យចូលបង្ហាញខ្លួនបាន។[28]

### ៣.១. ការឃាត់ខ្លួន

ដើម្បីសម្រួលដល់កិច្ចស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស លើសពីនេះមន្ត្រីនគរបាលយុត្តិធម៌ក៏អាចស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីព្រះរាជអាជ្ញាដើម្បីឃាត់ខ្លួនបុគ្គលដែលអាចផ្ដល់ព័ត៌មាន តែមិនព្រមផ្ដល់ព័ត៌មាន។ ក្នុងនេះដែរការឃាត់ខ្លួននេះមានថិរវេលា៤៨ម៉ោង គិតចាប់ពីពេល ដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ក៏ប៉ុន្តែមន្ត្រីនគរបាលយុត្តិក៏អាចស្នើសុំការពន្យាពេលនៃការឃាត់ខ្លួនជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា អំពីការពន្យាពេលនៃការឃាត់ខ្លួនបានប្រសិនបើមានតម្រុយដែលបង្ហាញពីពិរុទ្ធភាពលើ បុគ្គលដែលបានឃាត់ខ្លួនទាក់ទងទៅនឹងបទឧក្រិដ្ឋ។ ដោយការពន្យាពេលនេះមិនអាចលើសពី២៤ម៉ោងឡើយ ហើយការពន្យាពេលនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុដើម្បីដាក់ចូលទៅក្នុងសំណុំរឿង។

គួកត់សម្គាល់ផងដែរថា ការពន្យាពេលនៃការឃាត់ខ្លួននេះពុំត្រូវបានអនុវត្តចំពោះ អនីតិជនឡើយ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនអនីតិជនបានផងដែរគឺ ចំពោះ បទឧក្រិដ្ឋអនីតិជនដែលមានអាយុពី១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនលើសពី ៣៦ម៉ោងបានឡើយ ចំពោះបទមជ្ឈិមចំពោះអនីតិជន ដែលមានអាយុពី១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំមិនអាចត្រូវឃាត់ខ្លួនលើសពី ២៤ម៉ោងបានឡើយ ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល៤៨ម៉ោងឡើយ។ ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុ

[27] មាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[28] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោង ឡើយ ចំណែកអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំវិញគឺ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។[29] លើសពីនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់បុគ្គល ដែលឃាត់ខ្លួនអំពីមូលហេតុនៃការឃាត់ខ្លួន និងសិទ្ធិ ដែលមានជំនួយរបស់មេធាវីគឺមានន័យថា គាត់អាចសុំសន្ទនាជាមួយមេធាវី ក៏ប៉ុន្តែបុគ្គលនោះមិនត្រូវមានការពាក់ព័ន្ធនៅក្នុងរឿង ព្រហ្មទណ្ឌឡើយ។[30] ក្នុងការឃាត់ខ្លួននេះផងដែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយមានឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន, អត្តសញ្ញាណ នៃបុគ្គល ដែលត្រូវឃាត់ខ្លួន, មូលហេតុនៃការឃាត់ខ្លួន, ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន, ការឱ្យដឹងអំពីសិទ្ធិដែលបានបញ្ញត្តិនៃមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងឈ្មោះអ្នកបកប្រែក្នុងករណីចាំបាច់ ជាពិសេសមន្ត្រីនគរ បាលយុត្តិធម៌ត្រូវឱ្យបុគ្គលដែលត្រូវឃាត់ខ្លួនចុះហត្ថលេខា ឬផ្តិតមេដៃ ហើយប្រសិនបើបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ និងបន្ទាប់មកមន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យបុគ្គលនោះបានស្តាប់ផងដែរ។[31] ក្នុងនេះដែរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ អាចសុំជំនួយរបស់គ្រូពេទ្យនៅ ក្នុងការឃាត់ ខ្លួនដើម្បី ផ្ទៀងផ្ទាត់ពីស្ថានភាពសុខភាពថាតើសុខភាព បុគ្គលនោះសមស្រប ក្នុងការឃាត់ខ្លួនដែរឬទេ ប្រសិនបើមិនសមស្របទេមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាជាបន្ទាន់ ហើយការត្រួតពិនិត្យនេះតម្រូវឱ្យមានការចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាព ដើម្បីភ្ជាប់ក្នុងសំណុំរឿង។[32] ប្រសិនបើក្នុងករណីការឃាត់ខ្លួនអនីតិជនវិញ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ឪពុកម្តាយ ឬអ្នកតំណាងស្របច្បាប់ ឬ អ្នកទទួលភារកិច្ចលើអនីតិជន។[33] រាល់ការឃាត់ខ្លួនទាំងអស់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើបញ្ជីនៃការឃាត់ខ្លួនដើម្បីដាក់ជូនអាជ្ញាធរ តុលាការ និងកំណត់ហេតុសរុប នៃការឃាត់ខ្លួន ដែលកំណត់ហេតុនេះត្រូវដាក់ភ្ជាប់ជាមួយ សំណុំរឿង។[34]

បន្ទាប់ពីមន្ត្រីនគរបាលបានឃាត់ខ្លួនបុគ្គលពាក់ព័ន្ធហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវ បញ្ជូនជននោះទៅ នីតិវិធីបន្ទាប់។

[29] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[30] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[31] មាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[32] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[33] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[34] មាត្រា ១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ៣.២. ការបញ្ជូនខ្លួន

ក្រោយពីការផុតកំណត់រយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវឃាត់ខ្លួន សមត្ថកិច្ចត្រូវបញ្ជូនជននោះទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាពឡើងវិញ ដោយមានការសម្រេចនៃការដោះលែងនេះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា។[35]

### ៣.៣. វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

នៅក្នុងការស៊ើបអង្កេតករណីជាក់ស្តែងនេះ ពុំអនុញ្ញាតឲ្យមន្រ្តីនគរបាលយុត្តិធម៌ចេញបង្គាប់ឱ្យស្តាប់ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទឡើយ។ មន្រ្តីនគរបាលយុត្តិធម៌ពុំមាន អំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ ឬសារតាមអិនធើណែតឡើយ។[36] ក្នុងនេះដែរការស៊ើបអង្កេតជាក់ស្តែងគឺ មិនអាចលើសពី៧ថ្ងៃឡើយ ដោយគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស ក៏ប៉ុន្តែប្រសិនបើការស៊ើបអង្កេតមិនត្រូវបានបញ្ចប់នៅក្នុងចិរវេលានេះទេ មន្រ្តីនគរបាលយុត្តិធម៌អាចសុំយោបល់ទៅព្រះរាជអាជ្ញា[37] ហើយក្រោយពីបញ្ចប់ការស៊ើបអង្កេត មន្រ្តីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុរួមទាំងវត្ថុតាងទាំងអស់ជូនទៅព្រះរាជអាជ្ញា ដោយការបញ្ជូននេះត្រូវធ្វើជាមួយការបញ្ជូនខ្លួនរបស់បុគ្គលនោះផងដែរ។[38] កំណត់ហេតុនេះត្រូវចុះនិទ្ទេសដូចជា ឈ្មោះ និងឋានៈរបស់មន្រ្តីនគរបាលយុត្តិធម៌, អង្គភាពរបស់មន្រ្តីនោះ និងកាលបរិច្ឆេទដោយទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្រ្តីនគរបាលយុត្តិធម៌ ជាពិសេសនោះគឺកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានគឺត្រូវតែចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ។[39]

គួរកត់សម្គាល់ផងដែរថា ប្រសិនបើនីតិវិធីចាប់ពីមាត្រា ៩០ រហូតដល់មាត្រា១០៨ ពុំត្រូវបាន គោរពចំពោះ លក្ខខណ្ឌដាច់ខាតទេនោះ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។[40]

### ខ. ការស៊ើបអង្កេតបឋម

បន្ទាប់ពីបានដឹង អំពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្រ្តីនគរបាលយុត្តិធម៌ អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ដែលវិធាន

[35] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[36] មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[37] មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[38] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[39] មាត្រា ១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[40] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការនៃការអនុវត្តចំពោះ ការស៊ើបអង្កេតបឋមត្រូវអនុវត្តតាមមាត្រា ៩០, ៩៥, ១០៥ , ១០៧ និង១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[41]

*១. ការឆែកឆេរ*

នៅក្នុងករណីការស៊ើបអង្កេតជាបឋម ដែលទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានដោយ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ ទីកន្លែង។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ។

ក្នុងករណីអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីការអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវដឹកនាំដោយ ផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវ ចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាច ផ្តើមមុន ម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ឡើយ។ ត្រូវយកបញ្ញត្តិនៃមាត្រា ៩២ មកអនុវត្តក្នុងការចាប់យក វត្ថុតាង។[42]

*២. ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម*

នៅក្នុងការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយរាល់បុគ្គលដែល សង្ស័យថា បានចូលរួមប្រព្រឹត្តបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿង ហេតុក្នុងនេះដែរមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចស្នើសុំការយល់ព្រមពីព្រះរាជអាជ្ញាក្នុងការបញ្ជាឱ្យចូលខ្លួនរបស់បុគ្គលពាក់ព័ន្ធ ដោយមានកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា ដោយព្រះរាជអាជ្ញា។ បទបញ្ជានេះមានអានុភាព ឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលខ្លួន។[43]

[41] មាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[42] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[43] មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

*៣. ការស្តាប់ចម្លើយ*

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពី ការដកស្រង់ចម្លើយរបស់បុគ្គលពាក់ព័ន្ធ ដោយអាចរកជំនួយពីអ្នកបកប្រែបាន ហើយអ្នកបកប្រែត្រូវតែស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបក ប្រែឱ្យបានត្រឹមត្រូវ ដែលអ្នកបកប្រែមិនអាចត្រូវ បានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គល ដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយ ឡើយ។[44]

*៤. ការឃាត់ខ្លួន*

កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទបញ្ញត្តិស្តីពីការឃាត់ខ្លួន(ចំណុច គ) និង បញ្ញត្តិស្តីពីការបញ្ជូនខ្លួន(ចំណុច ឃ) នៃបញ្ញត្តិ ស្តីពីការ ស៊ើបអង្កេតករណីជាក់ស្តែងដូចដែលបានរៀបរាប់ខាងលើត្រូវយកមកអនុវត្ត។[45] ក្នុងនេះដែរ ប្រសិនបើមិនគោរពវិធានបញ្ញត្តិ មាត្រា ៩៦, ៩៧, ១០០, ១០៥, ១០៧, ១១៣ និងមាត្រា ១១៤ ដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាមទេ នោះនឹងនាំឱ្យមានមោឃភាពនៃនីតិ វិធី។

គ. ការប្រគល់ឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើប អង្កេត

នៅក្នុងការប្រប្រគល់ឱ្យម្ចាសដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើប អង្កេត ព្រះរាជអាជ្ញាមានសមត្ថកិច្ចក្នុងការបង្គាប់ឱ្យសមត្ថកិច្ចពាក់ព័ន្ធ ប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុនោះគ្មានប្រយោជន៍ក្នុងការសម្តែងការពិតទេ វៀរលែងតែវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ឬវត្ថុដែលកាន់កាប់ដោយខុសច្បាប់។ ប្រសិនបើសមត្ថកិច្ចពាក់ព័ន្ធពុំព្រមប្រគល់ទៅឱ្យម្ចាស់ដើមវិញទេ នោះម្ចាស់ នៃវត្ថុអាចដាក់ពាក្យប្តឹងទៅអគ្គព្រះរាជអាជ្ញាបាន។[46]

ក្នុងនេះដែរកាលបើ តុលាការដែលទទួលពាក្យបណ្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជ្ញា ឬអគ្គព្រះរាជអាជ្ញា មានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ។[47]

[44] មាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[45] មាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[46] មាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[47] មាត្រា ១២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# រដ្ឋប្បវេណី

# នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ដោយមេធាវី កុយ ដុល្លា*

## សេចក្តីផ្តើម

នៅក្នុងទំនាក់ទំនងរដ្ឋប្បវេណីតាមផ្លូវច្បាប់របស់រូបវន្តបុគ្គល និងនីតិបុគ្គល តាមរយៈការធ្វើសកម្មភាពគតិយុត្តដូចជា កិច្ចសន្យាលក់ទិញ, ប្រទានកម្ម, ភតិសន្យា និងកិច្ចសន្យាខ្ចីបរិភោគជាដើម ។ សកម្មភាពគតិយុត្តទាំងនោះនាំឲ្យមានការកកើតសិទ្ធិ និងកាតព្វកិច្ច ដែលភាគីម្ខាងហៅថាម្ចាស់បំណុល ដែលមានសិទ្ធិចំពោះកូនបំណុល និងភាគីម្ខាងទៀតហៅថាកូនបំណុល ដែលមានកាតព្វកិច្ចចំពោះម្ចាស់បំណុល ។

ទំនាក់ទំនងរបស់ម្ចាស់បំណុល និងកូនបំណុលមានភាពស្មុគស្មាញនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ឧទាហរណ៍នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានគោលបំណងឲ្យសងប្រាក់ហើយម្ចាស់បំណុលមានការបារម្ភចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលក្នុងការសងប្រាក់ ហើយមានការលំបាកក្នុងការអនុវត្តដោយបង្ខំនៅពេលអនាគត។ ម្ចាស់បំណុលអាចទៅពឹងពាក់តុលាការដើម្បីចេញដីសម្រេចរក្សាការពារ ដើម្បីទប់ស្កាត់ការប្រែប្រួលស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុលដែលជាទូទៅគេហៅថា ការរក្សាការពារ ហើយការរក្សាការពារបែងចែកជាពីរគឺ ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ដែលជាប្រធានបទត្រូវលើកយកបង្ហាញ និងការចាត់ចែងរក្សាការពារចំពោះសិទ្ធិលើបំណុលដែលគ្មានគោលបំណងឲ្យសងជាប្រាក់ ។

ការសរសេរលើប្រធានបទនេះគឺផ្តោតតែទៅលើ នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុប៉ុណ្ណោះ ពោលគឺមិនសរសេរដល់នីតិវិធីនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះទេ ហើយនីតិវីធីនេះត្រូវបានបែងចែកជាដំណាក់កាលមានដូចខាងក្រោម៖

១.អត្ថន័យនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

២.ការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

៣.ការចាត់តាំងចៅក្រមទទួលបន្ទុកដោយប្រធានសាលាដំបូង

៤.ការពិនិត្យពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

៥.ការធ្វើសេចក្តីបញ្ជាក់ដំបូង

---

* លោកមេធាវី កុយ ដុល្លា ជាសមាជិកមេធាវីនៅ **ក្រុមមេធាវី ធម្មសាស្ត្រ** មានអាសយដ្ឋានស្ថិតនៅ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ជាន់ទី១០ អាគារ៣៦ ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៦.ការពិនិត្យល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន

៧.ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

៨.ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

៩.បណ្តឹងឧបាស្រ័យ

១០.ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

## ១.អត្ថន័យនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ពាក្យថា "ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន" ក្នុងន័យទូទៅសំដៅលើ លិខិតដែលរឹបអូសយករបស់ទ្រព្យ តាមអំណាចច្បាប់សម្រាប់រយៈពេលណាមួយដើម្បីរងចាំរបស់អ្វីមួយជាស្ថាពរ ។ រីឯពាក្យថា "ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន" ក្នុងន័យគតិយុត្តវិញដែលមានចែងក្នុងមាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌ ១ ចំណុច ក បានផ្តល់និយមន័យលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺជា "ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសង ជាប្រាក់" ។

ជារួមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទាំងក្នុងន័យទូទៅ និងក្នុងន័យគតិយុត្ត គឺមានគោលដៅរួមដូចគ្នាដែលសំដៅលើ សេចក្តីសម្រេចរបស់អំណាចរដ្ឋដែលរឹបអូសវត្ថុ (ចលនវត្ថុ ឬ អចលនវត្ថុ) ក្នុងអំឡុងពេលណាមួយ ដើម្បីរងចាំការអនុវត្តជាស្ថាពរ ។

## ២.ការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ជាទូទៅ តុលាការអាចចាត់ការនីតិវិធីទៅបានទាល់តែម្ចាស់បំណុលដាក់ពាក្យសុំទៅតុលាការដែលមានសមត្ថកិច្ច ហើយពាក្យសុំនោះត្រូវសរសេរចំណុចជាសារធាតុដែលច្បាប់បានតម្រូវ។ ក៏ប៉ុន្តែបញ្ហានៅត្រង់ថា ប្រជាពលរដ្ឋភាគច្រើនពុំអាចសរសេរពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបានដោយខ្លួនឯងនោះទេ ដោយសារកត្តាចំណេះដឹងផ្នែកច្បាប់ដែលទាមទារល័ក្ខខ័ណ្ឌច្បាស់លាស់តាមមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះថាបើពួកគាត់ សរសេរពាក្យសុំពុំបានត្រឹមត្រូវ តុលាការពុំអាចធ្វើចំណាត់ការនីតិវិធីបាននោះទេ ច្បាស់ជាតុលាការបង្គាប់ឲ្យកែតម្រូវពាក្យសុំជាមិនខាន ។

បន្ទាប់ពីសរសេរពាក្យសុំនោះរួចហើយ ពាក្យសុំនោះត្រូវដាក់ចូលសាលាដំបូងតាមរយៈលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដោយមានការវាយត្រាចូលត្រឹមត្រូវ និងត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥០០០ រៀល (ប្រាំពាន់រៀល) ចូលជាថវិការដ្ឋ ។

## *២.១.តុលាការដែលមានសមត្ថកិច្ច*

យោងតាមមាត្រា ៥៤០ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ពីតុលាការ ដែលមានសមត្ថកិច្ចថា "រឿងក្ដីនៃដីកាសម្រេចរក្សាការពារត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ " ។

មាត្រាខាងលើបានកំណត់សមត្ថកិច្ចតុលាការជារួមនៅក្នុងនីតិវិធីរក្សាការពារ។ ប៉ុន្តែបើតាមមាត្រានេះ យើងអាចទាញចេញបានថានៅក្នុងការរឹបអូសជាបណ្ដោះអាសន្នមានសមត្ថកិច្ចតុលាការចំនួនពីរ គឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី និងតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ហើយវាជាតុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខទៀតផង (មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ហេតុដូច្នេះ តើតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី និងតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ននោះមានន័យយ៉ាង ដូចម្ដេច ?

**តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដីៈ** គឺជារឿងក្ដីនៃបណ្ដឹងដែលសម្រេចសេចក្ដីពាក់ព័ន្ធទៅនឹងសិទ្ធិដែលត្រូវរក្សាការពារ អាចជានីតិវិធីបណ្ដឹងជាអាទិ៍ ។ ឧទាហរណ៍ A ដាក់ពាក្យ បណ្ដឹងទាមទារប្រាក់ពី B នៅតុលាការ C ដូចនេះតុលាការដែលមានសមត្ថកិច្ចនៃការរឹបអូសជា បណ្ដោះអាសន្ន គឺតុលាការ C (តុលាការនៃការជំនុំជម្រះលើកទី១) ។ ប៉ុន្តែប្រសិនបើយើងពិនិត្យមើលមាត្រា ៥៤០ កថាខណ្ឌ ២ នៃនីតិវិធីរដ្ឋប្បវេណី វិញឃើញថា បើនីតិវិធីបណ្ដឹងនៅសាលាឧទ្ធរណ៍មានន័យថារឿងអង្គសេចក្ដីនៅសាលាឧទ្ធរណ៍ ដូច្នេះសាលាឧទ្ធរណ៍មានសមត្ថកិច្ចនៃការរឹបអូសជាបណ្ដោះអាសន្ន ។

***មាត្រា ៥៤០ កថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាៈ***

*"តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែបើអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍។ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍"*

ចុះប្រសិនបើអង្គសេចក្ដីត្រូវបានតុលាការកំពូលកំពុងចាត់ការ តើតុលាការណាដែលមានសមត្ថកិច្ច ?

ក្នុងករណីដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការ នៅក្នុងនីតិវិធីនៃបណ្ដឹងសាទុក្ខនោះ ត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញ ពោលគឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការជំនុំជម្រះលើកទី១ ។

តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្នៈ វត្ថុនៅទីនេះត្រូវបានបែងចែកជាចលនវត្ថុ និងអចលនវត្ថុ ប៉ុន្តែយើងលើកយកតែសមត្ថកិច្ចលើទីកន្លែងដែលអលចនវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្នប៉ុណ្ណោះ ។

***មាត្រា ១២០ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី បានឲ្យនិយមន័យអចលនវត្ថុថាៈ***

*"អចលនវត្ថុសំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្ដូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍" ។*

តាមរយៈមាត្រាខាងលើយើងអាចកំណត់សមត្ថកិច្ចបានថា បើអចលនវត្ថុទាំងនោះស្ថិតនៅដែនសមត្ថកិច្ចតុលាការណា គឺតុលាការនោះមានសមត្ថកិច្ចនៃការរឹបអូសជាបណ្ដោះអាសន្ន។ ប៉ុន្តែការដឹងអំពីសមត្ថកិច្ចតុលាការដែលបានបញ្ជាក់ខាងលើនៅពុំទាន់គ្រប់គ្រាន់នោះទេ យើងត្រូវដឹងថាតើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះត្រូវសរសេរចំណុចសំខាន់ៗ
អ្វីខ្លះដែលច្បាប់បានទាមទារ ។

### *២.២.ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន*

ជាគោលការណ៍ច្បាប់ ពាក្យសុំត្រូវសរសេរជាលាយល័ក្ខណ៍អក្សរដូចពាក្យបណ្ដឹងនៅនីតិវិធីបណ្ដឹងផងដែរដើម្បីធានាភាពច្បាស់លាស់ និងងាយស្រួលដល់តុលាការធ្វើចំណាត់ការនីតិវិធី (មាត្រា ៥៣៤ ក្រមនីតិវិធីរដ្ឋប្បវេណី) ។

ទោះបីមាត្រា ៥៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ជាក់ថាពាក្យសុំត្រូវសរសេរជាលាយល័ក្ខណ៍អក្សរគ្រាន់តែជាល័ក្ខខ័ណ្ឌទម្រង់ប៉ុណ្ណោះ ។

យោងតាមមាត្រា ៥៤១ កថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតម្រូវឲ្យសរសេរចំណុចជាសារធាតុនៅក្នុងពាក្យសុំមានដូចជាៈ

-ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកតំណាងដែលច្បាប់បានកំណត់សំដៅដល់៖ អ្នកអាណាព្យាបាលសម្រាប់អនីតិជន, អ្នកអាណាព្យាបាលទូទៅសម្រាប់ជននៅក្រោមអាណាព្យាបាលទូទៅ) ។

-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) ដែលអ្នកដាក់ពាក្យសុំទាមទារ គឺជាកម្មវត្ថុនៃការសុំចេញដីកាសម្រេច ដែលអ្នកដាក់ពាក្យសុំត្រូវបញ្ជាក់អត្តសញ្ញាណអចលនវត្ថុ ដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ននោះឲ្យបានច្បាស់លាស់ ។

-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (គប្បីបញ្ជាក់ឲ្យច្បាស់អំពីទំហំសិទ្ធិដែលមានគោលបំណងឲ្យសងប្រាក់នោះ និង បញ្ជាក់ពីអង្គហេតុនៃការកកើតនៃសិទ្ធិដែលនឹងត្រូវ

រក្សាការពារ ឧទាហរណ៍ ក្នុងកិច្ចសន្យាខ្ចីប្រាក់កាលបរិច្ឆេទនៃការសងប្រាក់បានមកដល់ តែកូនបំណុលពុំអនុវត្តកាតព្វកិច្ចសងប្រាក់នោះទេ)។

-ភាពចាំបាច់នៃការរក្សាការពារ (ការរឹបអូសជាបណ្តោះអាសន្ន) ។

បន្ថែមពីលើនេះមាត្រាខាងលើក៏ឲ្យអ្នកដាក់ពាក្យសុំសរសេរឲ្យច្បាស់លាស់ និងសរសេរភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

ទោះបីជាយ៉ាងណាក៏ដោយពាក្យសុំគ្រាន់តែជាល័ក្ខខ័ណ្ឌទម្រង់ និងមូលដ្ឋានប៉ុណ្ណោះ ហើយការរឹបអូសជាបណ្តោះអាសន្នទាមទារល័ក្ខខ័ណ្ឌមួយចំនួនទៀតដែលច្បាប់បានតម្រូវ ។

## ៣.ការចាត់តាំងចៅក្រមទទួលបន្ទុកដោយប្រធានសាលាដំបូង

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវបញ្ជូនពាក្យសុំដែលគេដាក់ចូលមកលេខាធិដ្ឋានរដ្ឋបាលនោះ ទៅប្រធានសាលាដំបូង ។ ក្រឡាបញ្ជីដែលបំពេញការងារជាមួយប្រធានសាលាដំបូងនឹងពិនិត្យលំដាប់វេនដោយអនុលោម តាមដីកាសម្រេចបែងចែកសំណុំរឿងថាតើ ពាក្យសុំដល់វេនលំដាប់របស់ចៅក្រមរូបណា ហើយក្រឡាបញ្ជីដាក់ជូនប្រធានសាលាដំបូងដើម្បីពិនិត្យ និងសម្រេចអំពីលំដាប់វេនចៅក្រម ដោយធ្វើកំណត់បង្ហាញ ចៅក្រមទទួលបន្ទុករឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

## ៤.ការពិនិត្យពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

នៅពេលចៅក្រម ទទួលបន្ទុករឿងក្តីទទួលបានសំណុំរឿងដែលចាត់តាំងដោយប្រធានសាលាដំបូង ចៅក្រមពិនិត្យសំណុំរឿង និងពាក្យសុំ ជាពិសេសចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

តាមមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ក្នុងការអនុវត្តជាក់ស្តែង ក្រឡាបញ្ជីជួយលោកចៅក្រមក្នុងការពិនិត្យកិច្ចការនេះ និងរាយការណ៍ជូនលោកចៅក្រម) ។ ករណីពាក្យសុំនោះពុំត្រឹមត្រូវតាមល័ក្ខខ័ណ្ឌមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ តុលាការនឹងចេញដីកាបង្គាប់ឲ្យកែត្រូវពាក្យសុំនោះឲ្យបានត្រឹមត្រូវវិញ ហើយប្រសិនបើម្ចាស់បំណុល (អ្នកដាក់ពាក្យសុំ) ពុំព្រមកែតម្រូវតាមដីកាបង្គាប់ឲ្យកែតម្រូវក្នុងអំឡុងពេលកំណត់នោះទេ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ។ ម្ចាស់បំណុលមានសិទ្ធិប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ចំពោះដីកាសម្រេចលើកចោលពាក្យសុំនោះ ។ ផ្ទុយទៅវិញបើពាក្យសុំនោះមានលក្ខណៈត្រឹមត្រូវអស់ហើយ តុលាការនឹងធ្វើចំណាត់ការបន្ត ដោយបង្គាប់ឲ្យបង់ពន្ធប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ និងធ្វើការកោះអញ្ជើញម្ចាស់បំណុលធ្វើនីតិវិធីសេចក្តីបញ្ជាក់ដំបូង ។ ប៉ុន្តែជាទូទៅតុលាការ ពុំកោះអញ្ជើញដើម្បីធ្វើសេចក្តីបញ្ជាក់ដំបូងនោះទេ គឺតុលាការពិនិត្យភស្តុតាងរបស់

ម្ចាស់បំណុលតែម្តង ថាតើមានភស្តុតាងគ្រប់គ្រាន់សម្រាប់ការទាមទារក្នុងការរឹបអូសបណ្តោះអាសន្ននេះដែរ ឬ ទេ ។

## ៥.ការធ្វើសេចក្តីបញ្ជាក់ដំបូង

ផ្អែកតាមខ្លឹមសារមាត្រា ៥៤១ កថាខណ្ឌ ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលកំណត់ កាតព្វកិច្ចឲ្យអ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល) ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងឲ្យច្បាស់អំពីទំហំសិទ្ធិដែលមានគោលបំណងឲ្យសងប្រាក់នោះ និងបញ្ជាក់ពីអង្គហេតុនៃការកកើតនៃសិទ្ធិដែល នឹងត្រូវរក្សាការពារដែលមាត្រាខាងលើប្រើពាក្យ "សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ" និងត្រូវបញ្ជាក់ពី "ភាពចាំបាច់នៃការរក្សាការពារ" (ការរឹបអូសជាបណ្តោះអាសន្ន) ។

តើការធ្វើសេចក្តីបញ្ជាក់ដំបូងស្តីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ" និងត្រូវបញ្ជាក់ពី "ភាពចាំបាច់នៃការរក្សាការពារ" តាមវិធីយ៉ាងដូចម្តេច ?

*យោងតាមមាត្រា ៥៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីការអនុវត្តដូចគ្នាតាមបញ្ញត្តិពីគន្ថី ២ ដល់គន្ថី ៤ បានបញ្ជាក់ថា "បញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស" ។*

ហេតុដូច្នេះបើបញ្ញត្តិពិសេសស្តីពី ការចាត់ចែងរក្សាការពារពុំមានចែងនោះទេ គេអាចយកបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មកប្រើប្រាស់បាន ។

នៅក្នុងគន្ថីទី ២ ខាងលើ គេឃើញមានមាត្រាមួយដែលនិយាយពីសេចក្តីបញ្ជាក់ដំបូង ហើយសេចក្តីបញ្ជាក់ដំបូងនេះត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន (មាត្រា ១៣១ ក្រមនីតិវិធីរដ្ឋប្បវេណី) ។ ភស្តុតាងនៅទីនេះសំដៅទៅលើភស្តុតាងដែលមានចែងនៅក្នុងគន្ថីទី ២ ជំពូកទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី រួមមាន៖ ការសាកសួរសាក្សី, ការសាកសួរភាគី, កោសល្យវិច័យ , ភស្តុតាងជាឯកសារ និងការត្រួតពិនិត្យ ។ ប៉ុន្តែបញ្ហានៅត្រង់ថា តើភស្តុតាងទាំងនោះអាចពិនិត្យបានភ្លាមៗដែរឬទេ? ទើបតុលាការទទួលយកព្រោះការរឹបអូសជាបណ្តោះអាសន្ន ទាមទារភាពឆាប់រហ័ស និងធ្វើឡើងដោយសំងាត់ ។ ហេតុនេះហើយ ការប្រគល់កិច្ចការស្រាវជ្រាវ ការចេញដីកាបង្គាប់ឲ្យផ្តល់ឯកសារ ឬការសាកសួរសាក្សីដែលទាមទារឲ្យមានការកោះហៅ ជាអាទិ៍ មិនអាចធ្វើបានទេ។[92]

ក្រោយអ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល) បានធ្វើសេចក្តីបញ្ជាក់ដំបូងរួចហើយ ប្រសិនបើតុលាការយល់ឃើញថា ពុំមានល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នត្រឹមត្រូវនោះទេ តុលាការ

[92] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ការអនុវត្តដោយបង្ខំ និងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ទំព័រ ១៩៩ ។

លើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយទុកសិទ្ធិឲ្យអ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល) ប្ដឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង (មាត្រា ៥៤៤ ក្រមនីតិវិធីរដ្ឋប្បវេណី) ។ ផ្ទុយទៅវិញ តុលាការយល់ឃើញថាម្ចាស់បំណុលមានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ពីការទាមទារនោះតុលាការសម្រេចសេចក្ដី ដោយចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដោយកំណត់កម្មវត្ថុជាក់លាក់ (អត្តសញ្ញាណអចលនវត្ថុច្បាស់លាស់) ដោយហេតុថានីតិវិធីរឹបអូសជាបណ្ដោះអាសន្ន ធ្វើឡើងដោយតុលាការត្រឹមចេញដីកាសម្រេចប៉ុណ្ណោះ (មាត្រា ៥៣៥ កថាខណ្ឌ ១ ក្រមនីតិវិធីរដ្ឋប្បវេណី) ហើយដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ តុលាការអាចបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគបាន ដើម្បីជាការធានា និងជៀសវាងប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលធ្ងន់ធ្ងរ ។ ឧទាហរណ៍ A ជាម្ចាស់បំណុលមានសិទ្ធិលើបំណុលចំពោះ B ចំនួន ១០ ០០០ ដុល្លារអាមេរិក ហើយ A បានសុំរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុរបស់ B ដែលមានតម្លៃរហូតដល់ ៩០ ០០០ ដុល្លារអាមេរិក ករណីបែបនេះគេជឿថាតុលាការនឹងបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគជាក់ជាមិនខានដោយសារតម្លៃអចលនវត្ថុនោះមានតម្លៃច្រើនជាងបំណុលដែលជំពាក់ច្រើនពេក ។ ប៉ុន្តែការអនុវត្តជាក់ស្ដែងមួយចំនួនក៏ឃើញមានតុលាការពុំបានបង្គាប់ឲ្យដាក់ប្រាតិភោគដែរ ព្រោះជាអំណាចឆន្ទានុសិទ្ធិរបស់តុលាការ ។

ភ្ជាប់ជាមួយដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការក៏ត្រូវកំណត់ចំនួនទឹកប្រាក់រំដោះដើម្បីរួចផុតពីការរឹបអូសជាបណ្ដោះអាសន្ននេះ ។

## ៦.ការពិនិត្យល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន

តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមពាក្យសុំបានទាល់តែបំពេញល័ក្ខខ័ណ្ឌមួយចំនួនមានដូចជា៖ សិទ្ធិនោះមានគោលបំណងឲ្យសងជាប្រាក់, សិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ និងភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។ ល័ក្ខខ័ណ្ឌទាំងនេះត្រូវបានទាញចេញពីខ្លឹមសារមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

### *៦.១.សិទ្ធិដែលមានគោលបំណងឲ្យសងជាប្រាក់*

យោងតាមមាត្រា ៥៤៥ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា "ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចចេញបានចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ" ។

មាត្រាខាងលើបានកំណត់យ៉ាងតឹងរឹង លើការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅបានទាល់តែសិទ្ធិលើបំណុលមានគោលបំណងឲ្យសងជាប្រាក់ប៉ុណ្ណោះ អាចជាកិច្ចសន្យាខ្ចីប្រាក់ជាអាទិ៍ ។

*៦.២.សិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់*

ក្រៅពីល័ក្ខខ័ណ្ឌសិទ្ធិដែលមានគោលបំណងឲ្យសងជាប្រាក់ខាងលើ ទោះបីជាសិទ្ធិលើបំណុលនោះភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយក៏តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះ អាសន្នបានផងដែរ នេះបើយោងតាមមាត្រា ៥៤៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តើសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់មានអត្ថន័យដូចម្ដេច ?

***មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណីបានចែងថា***

*"ការខ្ចីបរិភោគសំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងហៅថាអ្នកខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុង ពេលដែលមានកំណត់ ឲ្យទៅភាគីម្ខាងទៀត ហៅថា អ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ"*

***មាត្រា ៥៩៤ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណីបានចែងថា***

*"ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យសងវត្ថុដែលជាកម្មវត្ថុបានឡើយ រហូតដល់ពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទនៃកិច្ចសន្យា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលហេតុដែលបានកំណត់ក្នុងមាត្រា ៣៣១ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះបានកើតឡើង"។*

បញ្ញត្តិខាងលើបានរំលេចជាទ្រឹស្ដីទូទៅក្នុងកិច្ចសន្យាខ្ចីបរិភោគប៉ុណ្ណោះ ។ ប៉ុន្តែនៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះក៏អាចមានកម្មវត្ថុជាប្រាក់ផងដែរ ដែលជាប់ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន ។ ជាពិសេសកិច្ចសន្យាដែលមានកំណត់រយៈពេល បើមិនទាន់ដល់ពេលកំណត់ត្រូវសងប្រាក់នោះទេ អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យអ្នកខ្ចីអនុវត្តករណីយកិច្ចសងប្រាក់ ហើយក៏មិនអាចទាមទារតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបានឡើយ ។ ឧទាហរណ៍ A (អ្នកខ្ចី) បានធ្វើកិច្ចសន្យាខ្ចីប្រាក់ពី B (អ្នកឲ្យខ្ចី) ចំនួន ១០ ០០០ ដុល្លារអាមេរិក កាលពីថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៩ ដោយ A សន្យានឹងសងប្រាក់ទៅ B នៅកាលបរិច្ឆេទថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៩ តាមកិច្ចសន្យា ។ ដូច្នេះបើកាលបរិច្ឆេទថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៩ មិនទាន់កន្លងផុតទេ B មិនអាចទាមទារតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបាននោះទេ ។

### *៦.៣.ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន*

ត្រឹមតែមានកម្មវត្ថុដែលមានសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់នៅមិនទាន់គ្រាប់គ្រាន់នោះទេ ការរឹបអូសជាបណ្តោះអាសន្នត្រូវតែផ្អែកលើភាពចាំបាច់ក្នុងការរឹបជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ ។

ផ្អែកតាមខ្លឹមសារមាត្រា ៥៤៥ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានផ្តល់ជាល័ក្ខខ័ណ្ឌដែលអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្នុងករណីមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។ ចំណុចនេះគេទុកឲ្យតុលាការធ្វើការវិនិច្ឆ័យដោយផ្អែកលើអំណាចឆន្ទានុសិទ្ធិ ដោយផ្អែកលើស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ឬកត្តាកូនបំណុលផ្ទាល់ និងកត្តាផ្សេងៗទៀត អាចថាបើមិនរឹបអូសជាបណ្តោះអាសន្នទេ នឹងមានការលំបាកក្នុងការអនុវត្តដោយបង្ខំ ឬ មិនអាចអនុវត្តដោយបង្ខំបាន ។ ប៉ុន្តែយើងអាចសាកល្បងផ្តល់ឧទាហរណ៍ A (ជាកូនបំណុល) ជំពាក់ប្រាក់ B (ជាម្ចាស់បំណុល) ដល់ការកំណត់ត្រូវសងប្រាក់ តែ A ពុំសងប្រាក់នោះទេ ហើយ B ស៊ើបដឹងថា A ជំពាក់ប្រាក់ជាមួយម្ចាស់បំណុលច្រើននាក់ ហើយ A មានអចលនវត្ថុតែមួយប៉ុណ្ណោះ និងកំពុងត្រូវផ្សព្វផ្សាយលក់ទៀតផង។ ការដែល A លក់អចលនវត្ថុនេះក៏មិនរំពឹងថាយកប្រាក់បានមកពីការលក់នេះមកសងប្រាក់ B នោះទេ។

ហេតុដូច្នេះបើមានស្ថានភាពបែបនេះកើតឡើងប្រាកដមែននោះ ច្បាស់ណាស់ B (ជាម្ចាស់បំណុល) នឹងលំបាកក្នុងការអនុវត្តដោយបង្ខំ ឬ មិនអាចអនុវត្តដោយបង្ខំបានទេ ហើយម្ចាស់បំណុលនឹងទៅពឹងពាក់តុលាការដើម្បីសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ។

បន្ទាប់ពីគេដាក់ពាក្យសុំ និងបានបំពេញល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុទើបអាចឈានដល់នីតិវិធីដែលតុលាការធ្វើការវិនិច្ឆ័យ និង ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។

## ៧.ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការអាចលើកចោល ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នកាលណាតុលាការយល់ឃើញថាពាក្យសុំ និង ការធ្វើសេចក្តីបញ្ជាក់ដំបូងនោះនៅមិនទាន់មានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ផ្ទុយទៅវិញតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុកាលណាតុលាការយល់ឃើញថា ម្ចាស់បំណុលបានធ្វើសេចក្តីបញ្ជាក់ដំបូងដោយមានភស្តុតាងត្រឹមត្រូវ និងជាពិសេសបំពេញល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន ។

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រង់សេចក្តីសម្រេចនៃដីកា តុលាការត្រូវបញ្ជាក់ពីការរឹបអូសជាបណ្តោះអាសន្ន លើអចលនវត្ថុដោយបញ្ជាក់ពីអត្តសញ្ញាណរួម មានប្រភេទ ទំហំ ទីតាំង ប័ណ្ណកម្មសិទ្ធិ (លិខិតផ្សេងទៀតបញ្ជាក់ពីអចលនវត្ថុ) ឬ ឈ្មោះ កម្មសិទ្ធិករ ។ បន្ថែមពីលើនេះតុលាការត្រូវកំណត់ចំនួនទឹកប្រាក់រំដោះ ដែលកូនបំណុលត្រូវផ្ញើមកតុលាការ ដើម្បីទទួលបានការ លុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។ ឧទាហរណ៍ កូនបំណុលត្រូវផ្ញើប្រាក់ចំនួន **៤០.០០០.០០០ រៀល (សែសិបលានរៀល)** ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរួចហើយ តុលាការត្រូវចាត់ក្រឡាបញ្ជីដែលបំពេញការងារជាមួយ ដើម្បីធ្វើការបញ្ជូនដីកាសម្រេចខាងលើទៅឲ្យម្ចាស់បំណុល និងកូនបំណុល ដើម្បីឲ្យភាគីបានដឹងពីខ្លឹមសារនៃដីកាសម្រេចនេះ ព្រោះកូនបំណុលមានសិទ្ធិប្តឹងតវ៉ាចំពោះដីកាសម្រេចនេះ ។ រីឯម្ចាស់បំណុលមានសិទ្ធិប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំក្នុងរយៈពេល ២ (ពីរ) សប្តាហ៍ ។ ហើយនៅពេលមានបណ្តឹងតវ៉ា តុលាការនឹងកោះហៅគូភាគីដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ក្រោយចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការថយទៅពិចារណាសម្រេច និងអាចលុបចោល ផ្លាស់ប្តូរ ឬ រក្សាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដដែល ដោយចេញដីកាសម្រេចលើពាក្យសុំតវ៉ា ហើយដីកាសម្រេចលើពាក្យសុំតវ៉ានេះ គូភាគីអាចប្តឹងជំទាស់បាន ។

## ៨.ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

នៅពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះចំពោះអចលនវត្ថុ ភ្ជាប់ជាមួយការកំណត់ទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នដែលជាការតម្រូវដោយច្បាប់ ។

***មាត្រា ៥៤៧ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា៖***

*"ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន" ។*

ដូចអ្វីដែលយើងបានដឹងហើយថា ការរឹបអូសជាបណ្តោះអាសន្ន ធ្វើឡើងចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ប៉ុណ្ណោះ ហើយម្ចាស់បំណុលមានការបារម្ភថាមានការលំបាកក្នុង ការអនុវត្តដោយបង្ខំ ឬ មិនអាចអនុវត្តដោយបង្ខំ ។ ត្រង់ចំណុចនេះស្តែងឲ្យឃើញថាគោលដៅតែមួយគត់របស់ម្ចាស់បំណុល ដែលសុំតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដើម្បីធានាសិទ្ធិដែលមានគោលបំណងឲ្យសងជាប្រាក់នាពេលអនាគត។ ហេតុដូច្នេះប្រសិនបើកូន

បំណុលបានដាក់ប្រាក់រំដោះតាមការកំណត់របស់តុលាការ ដើម្បីរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈសមហេតុណាស់ក្នុងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយហេតុថា៖

-ម្ចាស់បំណុលលែងមានការបារម្ភពីការអនុវត្តដោយបង្ខំនាពេលអនាគត ។

-ម្ចាស់បំណុលលែងមានភាពចាំបាច់ក្នុងការរឹបអូសជាបណ្តោះអាសន្ន ។

ទោះបីបញ្ញត្តិច្បាប់បានកំណត់ពីប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នយ៉ាងណាក្តីដែលជាវិធីសង្គ្រោះកូនបំណុល ពោលគឺរំដោះអចលនវត្ថុរបស់កូនបំណុលពីការរឹបអូសជាបណ្តោះអាសន្នក៏នៅមានវិធីសង្គ្រោះផ្សេងទៀតដែលអនុញ្ញាតឲ្យកូនបំណុលប្តឹងឧបាស្រ័យចំពោះ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះបានទៀតផង ។

## ៩.បណ្តឹងឧបាស្រ័យ

ពិតប្រាកដណាស់ នៅពេលតុលាការចេញសេចក្តីសម្រេចអាចមានភាគីណាមួយមិនពេញចិត្តទើបច្បាប់អនុញ្ញាតឲ្យមានបណ្តឹងឧបាស្រ័យ ។

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងតវ៉ារបស់ភាគីដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ (សាលក្រម សាលដីកា ឬ ដីកាសម្រេច) របស់ចៅក្រម ឬ តុលាការដើម្បីទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម[93] ។

ដោយឡែក នៅក្នុងរឿងរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុអាចមានរូបភាពបីយ៉ាងនៃបណ្តឹងឧបាស្រ័យ (សុំធ្វើការបែងចែកជាបីដើម្បីងាយស្រួលបកស្រាយ) ៖ បណ្តឹងតវ៉ា, បណ្តឹងតវ៉ារបស់តតិយជន និងបណ្តឹងជំទាស់ ប៉ុន្តែគប្បីដឹងថាពេលណាគេធ្វើបណ្តឹងតវ៉ា ហើយពេលណាគេធ្វើបណ្តឹងជំទាស់ ព្រោះនីតិវិធីនីមួយៗមានលំដាប់លំដោយតាមច្បាប់ ។

### *៩.១.បណ្តឹងតវ៉ារបស់កូនបំណុល*

ជាគោលការណ៍ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញដោយពុំចាំបាច់សាកសួរកូនបំណុលនោះទេ តែក្រោយពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវបញ្ជូនដីកានេះទៅឲ្យភាគី (សំដៅដល់កូនបំណុល និងម្ចាស់បំណុល) (មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី) ។

---

[93] សន្ទានុក្រមពាក្យច្បាប់ រៀបរៀងដោយឯកឧត្តម ឆយ អូន, ឥន យឿន, ងួន យ៉ាណា និង សៀន វិសាល ទំព័រ ១២៧

ប្រសិនបើកូនបំណុលមិនពេញចិត្តចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន កូនបំណុលអាចប្តឹងតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការដើម គឺតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥០ ក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា៖**

*"កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារទៅតុលាការដែលបានចេញដីកាសម្រេចនោះ"។*

**មាត្រា ៥៣៤ កថាខណ្ឌ ១ ចំណុច ត ក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា៖**

*"ពាក្យសុំដែលបានកំណត់ខាងក្រោមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ:ពាក្យសុំតវ៉ាចំពោះការរក្សាការពារ"*

ហេតុដូច្នេះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរជាដាច់ខាត ។

នៅពេលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកោះហៅភាគី ចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសាកសួរដែលភាគីអាចចូលរួមបាន ។

**មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា ៖**

*"តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសង ខាងអាចចូលរួមបាន" ។*

មាត្រាខាងលើបានធានាសិទ្ធិទាមទារឲ្យសាកសួរ គោលការណ៍ចំពោះមុខ មុននឹងតុលាការសម្រេចសេចក្តីអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ថាតើតុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ។

### *៩.២.បណ្តឹងតវ៉ារបស់តតិយជន*

ផ្អែកតាមមាត្រា ៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៅក្នុងរឿងអនុវត្តរក្សាការពារ ក្នុងនោះឃើញមានមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីបណ្តឹងតវ៉ារបស់តតិយជន និងមាត្រា ៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ការសម្រេចផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ) ។

***មាត្រា ៣៦៥ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា៖***

*"តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំអាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឲ្យអនុញ្ញាតការអនុវត្តដោយបង្ខំចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន" ។*

ដោយហេតុថាមាត្រាខាងលើយកមកអនុវត្តចំពោះរឿងរក្សាការពារផងដែរ ដូច្នេះតតិយជនដែលប៉ះពាល់ផលប្រយោជន៍កើតចេញពីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺតតិយជននោះអាចប្តឹងតវ៉ាបានដែលគេហៅថា បណ្តឹងរបស់តតិយជន និងអនុវត្តនីតិវិធីដូចនីតិវិធីបណ្តឹងផងដែរ (មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់) ។

នីតិវិធីនៅពេលមានបណ្តឹងតវ៉ារបស់តតិយជន មានភាពខុសប្លែកពីបណ្តឹងតវ៉ាធម្មតារបស់កូនបំណុល ហើយនីតិវិធីនោះឃើញមានចែងនៅក្នុងមាត្រា ៣៦៧ កថាខណ្ឌទី ១ បានចែងថា៖

*"នៅក្នុងករណីដែលមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ ពាក្យបណ្តឹងតវ៉ារបស់តតិយជន បើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលបានទទួលពាក្យបណ្តឹង អាចបង្គាប់ឲ្យ ផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយជាអាទិ៍) នៃក្រមនេះ នៅក្នុងសាលក្រមចុងក្រោយ" ។*

តាមខ្លឹមសារមាត្រានេះបានអនុញ្ញាត ឲ្យតុលាការដែលបានទទួលពាក្យបណ្តឹងតវ៉ារបស់តតិយជននោះអាចបង្គាប់ឲ្យផ្អាកការអនុវត្តសិន ដើម្បីរង់ចាំតុលាការសម្រេចសេចក្តីចុងក្រោយ ដោយចេញសាលក្រមចុងក្រោយដែលអាចលុបចោល ឬ ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវការអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ។

### *៩.៣.បណ្តឹងជំទាស់*

ដូចយើងដឹងស្រាប់ ហើយថាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបញ្ជូនទៅភាគីទាំងកូនបំណុល និងម្ចាស់បំណុល ហើយកាលបើកូនបំណុលមិនពេញចិត្តចំពោះដីកាសម្រេចរឹបអូស ជាបណ្តោះអាសន្ន គឺគាត់អាចប្តឹងតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ។ ករណីមានពាក្យសុំតវ៉ា តុលាការនឹងចេញដីកាសម្រេចលើពាក្យសុំតវ៉ា ដែលអាចលុបចោល ឬ ផ្លាស់ប្តូរ ឬ ទទួលស្គាល់ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ។ ច្បាស់ណាស់នៅពេលមានដីកាសម្រេចលើពាក្យសុំតវ៉ាបែបនេះ អាចមានភាគីខាងម្ចាស់បំណុល ឬ កូនបំណុលមិនសប្បាយចិត្តដោយប៉ះពាល់ដល់ផលប្រយោជន៍ពួកគាត់ ទើបច្បាប់អនុញ្ញាតឲ្យប្តឹងជំទាស់ ។

បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ (ដែលជាតុលាការនៃបណ្តឹងជំទាស់) ដើម្បីទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរដីកាសម្រេចដើម[94] ។

ហេតុដូច្នេះនៅក្នុងរឿងរឹបអូសជាបណ្តោះអាសន្នច្បាប់បើកផ្លូវ ឲ្យមានការប្តឹងជំទាស់លើដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្ន ។ ត្រង់ចំណុចនេះឃើញមានចែងនៅក្នុងមាត្រា ៥៦១ កថាខណ្ឌ ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ១០.ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានលុបចោលតាមនីតិវិធីនៃពាក្យសុំ របស់កូនបំណុល ប៉ុន្តែដីកាសម្រេចនេះក៏អាចត្រូវបានលុបចោលផងដែរដោយការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី និងការផ្លាស់ប្តូរស្ថានភាព ។

### *១០.១.ការលុបចោលដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី*

ការរឹបអូសជាបណ្តោះអាសន្នគ្រាន់តែជានីតិវិធីបណ្តោះអាសន្ន ដើម្បីហាមឃាត់ការចាត់ចែងទ្រព្យ របស់កូនបំណុល ដើម្បីរង់ចាំការអនុវត្តដោយបង្ខំ ហេតុដូច្នេះនៅពេលតុលាការចេញ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវបង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី (នីតិវិធីបណ្តឹង ឬ នីតិវិធីមជ្ឈត្តកម្ម) ដើម្បីទទួលបានការសម្រេចសេចក្តីនៃរឿងដែលមានគោលបំណងឲ្យសងជាប្រាក់ (សាលក្រម) ហើយម្ចាស់អាចទទួលបានលិខិតអនុវត្តតាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីយកទៅអនុវត្តដោយបង្ខំបាន ។ ហេតុដូច្នេះការដាក់បណ្តឹងអង្គសេចក្តីជាល័ក្ខខ័ណ្ឌចាំបាច់ណាស់ បន្ទាប់ពីមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។ ម្ចាស់បំណុលត្រូវដាក់ឯកសារបញ្ជាក់ពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីទៅតុលាការដែលចេញរក្សាការពារក្នុងអំឡុងពេលសមរម្យដែល មិនតិចជាង ២ (ពីរ) សប្តាហ៍ តាមការបង្គាប់របស់តុលាការ ។

***មាត្រា ៥៥៧ កថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា៖***

*"១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារត្រូវបង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឲ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសម រម្យ តាមពាក្យសុំរបស់កូនបំណុល។*

*២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្តាហ៍ ។*

[94] សន្ទានុក្រមពាក្យច្បាប់ រៀបរៀងដោយឯកឧត្តម ឆយ អូន, ឥន យឿន, ងួន យ៉ាណា និង សៀន វិសាល ទំព័រ ១២៥

*៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។"*

### ១០.២.ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព

***យោងតាមមាត្រា ៥៥៨ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា ៖***

*"១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងៗទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្ដឹង អង្គសេចក្ដី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន*

*២-ចំពោះការផ្លាស់ប្ដូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង" ។*

ករណីដែលអាចលុបចោលដីកាសម្រេចរក្សការពារ ដោយយកមូលហេតុនៃការផ្លាស់ប្ដូរស្ថានភាពមានករណីធំពីរ ។ ករណីទី ១ គឺករណីដែលមានហេតុថ្មីដែលនាំឲ្យដីកាសម្រេចរក្សាការពារមានភាពមិនត្រឹមត្រូវ កើតឡើងក្រោយពេលចេញដីកាសម្រេចរក្សាការពារនោះ ។ ឯករណីមួយទៀត គឺករណីដែលហេតុនេះបានកើតឡើងរួចហើយនៅពេលចេញដីកាសម្រេចរក្សាការពារ តែកូនបំណុលបានដឹងអំពីហេតុនោះ ឬ អាចធ្វើសេចក្ដីបញ្ជាក់ដំបូង ក្រោយពេលចេញដីកាសម្រេចរក្សាការពារនោះ។ ជាឧទាហរណ៍ គឺ ករណីដែលសិទ្ធិដែលត្រូវបានរក្សាការពារបានរលត់ដោយសារការសង ជាដើម និងករណីដែលភាពចាំបាច់នៃការរក្សាការពារបានរលត់ ដោយសារស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលគ្រាន់បើឡើងវិញ [95]។

## សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវទាំងការអនុវត្តជាក់ស្ដែង និងទាំងបញ្ញត្តិច្បាប់ទៅលើនីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុនេះដែលជានីតិវិធីពិសេស ឬអាចថាថ្មីសម្រាប់អ្នកអនុវត្ត និងប្រជាពលរដ្ឋទូទៅផងដែរ ។ នីតិវិធីនេះមានប្រសិទ្ធិភាពក្នុងការអនុវត្ត ដោយហេតុថាករណីមួយចំនួនគ្រាន់តែតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលទទួលបានការសងប្រាក់ពីកូនបំណុល ដោយពុំចាំបាច់អនុវត្តដោយបង្ខំនោះទេ នេះគឺជា

[95] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ទំព័រ ៥៤៧

សញ្ញាណវិជ្ជមានសម្រាប់ម្ចាស់បំណុល ។ ទើបសំណុំរឿងរក្សាការពារមានការកើនឡើងជាលំដាប់ ធៀបនឹងឆ្នាំមុនៗ ដោយម្ចាស់បំណុលបានមើលឃើញពីប្រសិទ្ធិភាពពីបញ្ញត្តិច្បាប់ ក៏ដូចជាការអនុវត្តច្បាប់ផងដែរ ។ ទន្ទឹមនឹងនេះក៏នៅមានផលលំបាកចំពោះម្ចាស់បំណុលផងដែរ នៅពេលតុលាការកំណត់ឲ្យម្ចាស់បំណុលដាក់ប្រតិភោគជាល័ក្ខខ័ណ្ឌ ឲ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ប៉ុន្តែម្ចាស់បំណុលពុំមានលទ្ធភាពនោះ អាចចោទជាបញ្ហាចំពោះម្ចាស់បំណុលផងដែរ ។ ទោះបីនីតិវិធីនេះមានលក្ខណៈការពារម្ចាស់បំណុលច្រើនក៏ដោយ ក៏ប៉ុន្តែមុននឹងតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ តុលាការត្រូវពិនិត្យល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នយ៉ាងតឹងរឹងបំផុតដើម្បីជៀសវាង កុំឲ្យការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរបស់ម្ចាស់បំណុលក្លាយជាឧបករណ៍បំពានលើសិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល ។ ម្យ៉ាងវិញទៀតដើម្បីធានានូវគោលការណ៍ចំពោះមុខ និងសិទ្ធិទាមទារឲ្យសាកសួរ កូនបំណុលក៏មានសិទ្ធិតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ប្តឹងជំទាស់លើដីកាសម្រេចលើពាក្យសុំតវ៉ាផងដែរ នៅពេលដែលខ្លួនគិតថាសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនត្រូវបានគេបំពានយ៉ាងធ្ងន់ធ្ងរនោះ។

# សកម្មភាពរបស់គណៈមេធាវី

## ១.ទំនាក់ទំនងជាតិ និងអន្តរជាតិ

### ១.១ ទំនាក់ទំនងជាតិ

**លោក លីវ សុវណ្ណា អគ្គលេខាធិការរង និងសហការីរួមជាមួយប្រតិភូគណៈមេធាវីប្រចាំខេត្តកំពង់ចាម បានចុះជួបពិភាក្សាការងារ និងពិនិត្យទីតាំងសាងសង់បន្ទប់មេធាវីដាច់ដោយឡែក ក្នុងពន្ធនាគារខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ**

នៅថ្ងៃចន្ទ ០៣ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០២០ វេលាម៉ោង ៨:៤០នាទីព្រឹក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយលោក លីវ សុវណ្ណា អគ្គលេខាធិការរងតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមប្រធានគណៈមេធាវី និងលោកស្រីមេធាវី លឹម ច័ន្ទលីដា ប្រធាននាយកដ្ឋានរដ្ឋបាលគណៈមេធាវីនិងសហការីរួមជាមួយប្រតិភូគណៈមេធាវីប្រចាំខេត្តកំពង់ចាម បានចុះជួបពិភាក្សាការងារ និងពិនិត្យទីតាំងសាងសង់បន្ទប់មេធាវីដាច់ដោយឡែក ក្នុងពន្ធនាគារខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

នៅក្នុងពិធីនោះ ឯកឧត្តម ហ៊ុន ខី ប្រធានពន្ធនាគារ និងសហការី បានចូលរួមក្នុងកិច្ចពិភាក្សា ដោយក្តីរីករាយ និងយោគយល់ ព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថា ខាងពន្ធនាគារមានដីទុកសំរាប់សាងសង់បន្ទប់មេធាវីដាច់ដោយឡែកសំរាប់ជូនគណៈមេធាវី ក្នុងការសាងសង់ ៕
កិច្ចពិភាក្សានេះបានបញ្ចប់ដោយបរិយាកាសរីករាយ និងស្និតស្នាលបំផុត។



## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា

នៅថ្ងៃព្រហស្បតិ៍ទី ៦ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាពឯឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ សិក្ខាសាលាថ្នាក់ជាតិនេះរៀបចំឡើងដោយអនុលោមតាមលិខិតរបស់ ទីស្តីការ គណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតឲ្យអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) រៀបចំផ្តួចផ្តើមធ្វើច្បាប់ ស្តីពីកិច្ចការពារកុមារនៅកម្ពុជា និងមានគោលបំណងដើម្បីស្វែងយល់ពីច្បាប់ និងបទដ្ឋានគតិយុត្ត ដែលមានស្រាប់ និងសិក្សាពីបញ្ហាប្រឈមនិងភាពខ្វះចន្លោះក្នុងការអនុវត្តជាក់ស្តែង ព្រមទាំងបទពិសោធន៍និងការអនុវត្តល្អពីភាគី ពាក់ព័ន្ធសំដៅការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមារជាចម្បង។



## បេសកកម្មជួបជាមួយប្រធានពន្ធនាគារតាមបណ្តាខេត្ត

ចាប់ពីថ្ងៃទីថ្ងៃចន្ទ ២ រោច ដល់ ៤ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០-១២ ខែកុម្ភៈ ឆ្នាំ២០២០ លោកមេធាវី លីវ សុវណ្ណា អគ្គលេខាធិការរងគណៈមេធាវី និងលោកស្រីមេធាវី លឹម ច័ន្ទលីដា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក គណៈមេធាវី លោកស្រី

មេធាវី សួន ធារី បានចុះបេសកកម្មជួបជាមួយលោកប្រធានពន្ធនាគារតាមបណ្តាខេត្តចំនួន០៧ គឺ ពន្ធនាគារខេត្តកំពង់ធំពន្ធនាគារខេត្តព្រះវិហារ ពន្ធនាគារខេត្តឧត្តរមានជ័យ ពន្ធនាគារខេត្តប៉ៃលិន ពន្ធនាគារខេត្តបន្ទាយមានជ័យ ពន្ធនាគារខេត្តពោធិ៍សាត់ និងពន្ធនាគារខេត្តកំពង់ឆ្នាំង ដើម្បី ពិភាក្សាអំពីការសាងសង់បន្ទប់មេធាវីសម្រាប់សម្ភាសកូនក្តីក្នុងពន្ធនាគារ។ កិច្ចពិភាក្សានេះបញ្ចប់ ដោយបរិយាកាសរីករាយ និងទទួលលទ្ធផលជាផ្លែផ្កា ដោយបានឯកភាពគ្នាក្នុងការសាងសង់ បន្ទប់មេធាវីសម្រាប់សំភាសន៍កូនក្តីក្នុងពន្ធនាគារទាំង៧ពន្ធនាគារ ឱ្យរួចរាល់ក្នុងរយៈពេល០៣ខែ ខាងមុខនេះ។ សូមថ្លែងអំណរគុណដល់លោកប្រធានពន្ធនាគារ និងមេធាវីប្រតិភូគណៈមេធាវី តាម បណ្តាខេត្តទាំង៧ខាងលើ ដែលបានសហការជាមួយគណៈមេធាវីយ៉ាងល្អ ក្នុងការចូលរួមចំណែក លើកកម្ពស់វិស័យយុត្តិធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់ រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និង សភាពាណិជ្ជកម្មកម្ពុជា

នៅរសៀលថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២០ នៅទីស្នាក់ការ អគ្គនាយកដ្ឋានសភាពាណិជ្ជកម្មកម្ពុជា មានជំនួបរវាង គណៈប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូសភាពាណិជ្ជកម្មកម្ពុជា ដឹកនាំដោយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជាដើម្បី « ចុះហត្ថលេខាលើអនុស្សារណៈយោគយល់ រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និង សភាពាណិជ្ជកម្មកម្ពុជា»។

គោលបំណងនៃការចុះអនុស្សារណៈយោគយល់នេះ គឺដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នទាំងពីរនៅក្នុងវិស័យពាណិជ្ជកម្ម និងសេវាកម្មច្បាប់ ព្រមទាំងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក។ ជាមួយគ្នានេះផងដែរ អនុស្សារណៈនៃការយោគយល់ (MOU) នឹងរិតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក្នុងគោលដៅចូលរួមចែករំលែកព័ត៌មានដែលទាក់ទង នឹងការវិវឌ្ឍផ្នែកពាណិជ្ជកម្ម សេវាកម្មច្បាប់ និងចំណេះដឹងបទពិសោធន៍ផ្នែកច្បាប់ ជាពិសេសច្បាប់ ទាក់ទងនឹង វិស័យពាណិជ្ជកម្ម។ ពិធីនេះបានបញ្ចប់ដោយបរិយា- កាសរីករាយ និងស្និទស្នាលយ៉ាង ក្រៃលែង។





## ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី ដើម្បីជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងមន្ត្រីក្រោមឱវាទនៅទីស្តីការក្រសួងទេសចរណ៍

នាព្រឹកថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី ដើម្បីជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងមន្ត្រីក្រោមឱវាទនៅទីស្តីការក្រសួងទេសចរណ៍។ នៅក្នុងកិច្ចប្រជុំ ពិភាក្សានេះ ក្រសួងទេចរណ៍ បានស្នើសុំឱ្យគណៈមេធាវីជួយលើកិច្ចការច្បាប់ដល់ក្រសួង ហើយគណៈមេធាវីនៃ

ព្រះរាជាជាណាចក្រកម្ពុជា បានទទួលយកការស្នើសុំ ដោយចាត់តាំងមេធាវីចំនួន០៣រូប ដើម្បីបំពេញកិច្ចការងារច្បាប់ដល់ក្រសួង។ លើសពីនេះ ក្រសួងទេសចរណ៍ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នឹងចុះអនុស្សារណៈនៃការយោគយល់ (MOU) ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យច្បាប់នេះ នាដើម្បីចុះហត្ថលេខានាពេលអនាគត។ កិច្ចប្រជុំនេះបានបញ្ចប់នៅ ក្រោមបរិយាកាសរីករាយ ស្និទស្នាលរវាងស្ថាប័នទាំងពីរ។






**ឯកឧត្តម សួន វិសាល អញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នាទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃព្រហស្បត្តិ៍ ២ រោច ខែចៃត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី៩ខែមេសា ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូនៃគណៈមេធាវី អញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នាទីស្តីការក្រសួងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

នៅក្នុងការអញ្ជើញ និងពិភាក្សាការងារនេះ ឯកឧត្តម សួន វិសាល បានលើកពីសកម្មភាពការងារ និងសមិទ្ធិផលសំខាន់នានារបស់គណៈមេធាវីសម្រេចបានកន្លងមក។ ជាមួយគ្នានេះផងដែរ នៅក្នុងកិច្ចពិភាក្សានេះ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា ដើម្បីឲ្យការងារកាន់តែប្រសិទ្ធិភាពខ្ពស់ និងជាការរួមចំណែកកិច្ចការងារសង្គមក្រសួងនឹងផ្តល់ប្រព័ន្ធទូរស័ព្ទពិសេសមួយខ្សែ(Hotline)តាមការស្នើសុំរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីផ្តល់ភាពងាយស្រួលដល់ការទំនាក់ទំនងរបស់ប្រជាជនកម្ពុជាទៅកាន់មេធាវីការពារក្តីជូនជនក្រីក្រ។

ជាទីបញ្ចប់នៃការសម្តែងការគួរសម និងពិភាក្សានេះ ឯកឧត្តមប្រធានគណៈមេធាវីបានថ្លែងអំណរគុណ ដល់ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ចំពោះការគាំទ្រ និងខិតខំប្រឹងប្រែងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ការសំណេះសំណាលនេះបានបញ្ចប់ ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងភាតរភាពរវាងស្ថាប័នទាំងពីរ។





**ឯកឧត្តម សួន វិសាល អញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាទីស្តីការក្រសួងយុត្តិធម៌**

រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃព្រហស្បត្តិ៍ ០៣ រោច ខែចែត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០ខែមេសា ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូនៃគណៈមេធាវី អញ្ជើញចូលជួបសម្តែងការគួរសម និង

ពិភាក្សាការងារជាមួយឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងបានពិភាក្សាការងារមួយចំនួនដូចខាងក្រោម៖

១. កិច្ចសហការក្នុងកម្មវិធីជំនួយផ្នែកច្បាប់ និងការការពារក្តីជូនជនក្រីក្រដោយឥតគិតថ្លៃ

២. ការធ្វើវិសោធនកម្មច្បាប់លក្ខន្តិកៈមេធាវី

៣. ការចូលរួមក្នុងយុទ្ធនាការដោះស្រាយបញ្ហាកកស្ទះសំណុំរឿង និងភាពមិនប្រក្រតីនៅតាមតុលាការ

៤. កិច្ចសហការក្នុងការចងក្រងនិងផ្សព្វផ្សាយសាលក្រម សាលដីកាគំរូ ជាសាធារណៈ

ការសំណេះសំណាលនេះបានបញ្ចប់ ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងភាតរភាពរវាងស្ថាប័នទាំងពីរ។ ជាកិច្ចបញ្ចប់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានប្រគល់នូវ អាល់កុលលាងសម្អាតដៃមួយចំនួន ជូនគណៈមេធាវីដើម្បីប្រើប្រាស់នៅក្នុងគណៈមេធាវី ក្នុងគោលបំណងចូលរួមទប់ស្កាត់ការរីករាលដាលនូវជំងឺកូវីដ-១៩ ៕



### ១.២ ទំនាក់ទំនងអន្តរជាតិ

**លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានដឹកនាំគណៈប្រតិភូ ដើម្បីពិភាក្សាការងារជាមួយសហព័ន្ធមេធាវីម៉ាឡេស៊ី**

នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៥ កើត ខែបុស្ស ឆ្នាំ កុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

បានដឹកនាំគណៈប្រតិភូទៅប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាការងារជាមួយ សហព័ន្ធមេធាវីម៉ាឡេស៊ី ដោយផ្តោតលើកិច្ចការងារសំខាន់ៗដែលមានរបៀបវារៈដូចជា៖

- កម្មវិធីបណ្តុះបណ្តាល
- ការផ្លាស់ប្តូរបទពិសោធន៍រវាងមេធាវីកម្ពុជា និងម៉ាឡេស៊ី
- កិច្ចសហប្រតិបត្តិការនាពេលអនាគត

កិច្ចពិភាក្សានោះបានចែករំលែកនូវបទពិសោធន៍ល្អៗ រវាងគណៈមេធាវីទាំងពីររួមមាន ការការពារក្តីជូនជនក្រីក្រ កិច្ចសហការនៃបណ្តាប្រទេសក្នុងតំបន់ និងអនុស្សារណៈផ្សេងៗ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយបរិយាកាស រីករាយ និងស្និទ្ធស្នាលប្រកបដោយភាតរភាព។





## លោកមេធាវី សួន វិសាល និងគណៈប្រតិភូនៃគណៈមេធាវីបានចូលរួមកម្មវិធីច្បាប់ប្រចាំឆ្នាំ ២០២០

កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ លោកមេធាវីសួន វិសាល និងគណៈប្រតិភូនៃគណៈមេធាវីបានចូលរួមកម្មវិធីច្បាប់ប្រចាំឆ្នាំ ២០២០ ដែលរៀបចំដោយសហព័ន្ធមេធាវីម៉ាឡេស៊ី។ នៅក្នុងកម្មវិធីនេះផងដែរមានការចូលរួមពីថ្នាក់ដឹកនាំគណៈមេធាវីមកពី បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសជុំវិញពិភពលោក នៅក្នុងកម្មវិធីច្បាប់ប្រចាំឆ្នាំ២០២០ ដែលបានធ្វើឡើងនៅទីក្រុង Putrajaya ប្រទេសម៉ាឡេស៊ី។






## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកស្រីមេធាវី Elizabeth Bennett-Martin ជាមេធាវីនៅប្រទេសកាណាដា និងជាតំណាងរបស់អង្គការមូលនិធិការអប់រំច្បាប់សម្រាប់ស្ត្រីកម្ពុជា

នៅថ្ងៃច័ន្ទ ០៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកស្រីមេធាវី Elizabeth Bennett-Martin ជាមេធាវីនៅប្រទេសកាណាដា និងជាតំណាងរបស់អង្គការមូលនិធិការអប់រំច្បាប់សម្រាប់ស្ត្រីកម្ពុជា និងសហការី ដើម្បីជជែក និងពិភាក្សាការងារ។

នៅក្នុងកិច្ចប្រជុំនោះ លោកស្រី Elizabeth Bennett-Martin បានកោតសរសើរដល់គណៈមេធាវីកម្ពុជាដែលបានរៀបចំការប្រលងប្រណាំងចូលធ្វើមេធាវីប្រកបដោយតម្លាភាព ដែលនៅក្នុងនោះនិស្សិតស្ត្រីដែលក្រីក្រដែលបានទទួលឧត្ថម្ភគាំទ្រពីអង្គការរបស់លោកស្រី បានប្រលងជាប់ចំនួនប្រាំរូបផងដែរ។

នៅក្នុងកិច្ចប្រជុំសម្រេចបាន រួមមាន លោកស្រីមេធាវីនឹងផ្តល់ការឧត្ថម្ភគាំទ្រដល់និស្សិតស្ត្រីកម្ពុជាក្នុងការធ្វើជាអ្នកហាត់ការ នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រីមេធាវីនឹងផ្តល់នូវគ្រូឧទ្ទេសពាក់ព័ន្ធនឹងបច្ចេកទេសនៃការស្រាវជ្រាវ និងសរសេរអត្ថបទច្បាប់ សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មេធាវីកម្ពុជាផងដែរ។កិច្ចប្រជុំបានបញ្ចប់ទៅដោយបរិយាកាសរីករាយ។



## លោកមេធាវី សួន វិសាល ជួបប្រជុំជាមួយអតីតប្រធានគណៈមេធាវីនៃរដ្ឋវ៉ាស៊ីនតោនលោកមេធាវី សួន វិសាល ជួបប្រជុំជាមួយអតីតប្រធានគណៈមេធាវីនៃរដ្ឋវ៉ាស៊ីនតោន

នៅថ្ងៃអង្គារ ៥រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ ២០២០ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាលោកមេធាវីសួន វិសាល ប្រធានគណៈមេធាវីបានជួបពិភាក្សាការងារជាមួយលោក William D. Pickett អតីតប្រធានគណៈមេធាវី នៃរដ្ឋវ៉ាស៊ីនតោន និងសហការី។ នៅក្នុងជំនួបនេះលោកប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកមេធាវី កុយ នាម អគ្គលេខាធិការគណៈមេធាវី ធ្វើសេចក្តីសង្ខេបអំពីប្រវត្តិ និងការវិវឌ្ឍន៍ការងាររបស់គណៈមេធាវីកន្លងមក។ បន្ថែមពីលើនេះទៀត លោកប្រធានគណៈមេធាវីក៏បានបង្ហាញនូវតម្រូវការជាក់ស្តែងដែលគណៈមេធាវីបាន និងកំពុងជួបប្រទះ ហើយលោកក៏បានស្នើសុំទៅលោក William D. Pickett ផ្តល់នូវជំនួយបច្ចេកទេសមួយចំនួនជាពិសេសលើការផ្តល់នូវអ្នកជំនាញខាងស្រាវជ្រាវច្បាប់ និងសរសេរអត្ថបទច្បាប់ និងប្រព័ន្ធនិន្នំយច្បាប់សម្រាប់មេធាវីកម្ពុជាធ្វើការស្រាវជ្រាវផងដែរ។

លោក William D. Pickett បានទទួលយកនូវសំណើររបស់កម្ពុជា ហើយលោកនឹងអញ្ជើញគណៈប្រតិភូ នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៅធ្វើទស្សនកិច្ចសិក្សានៅសហរដ្ឋអាមេរិក ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។ នាពេលអនាគត គណៈមេធាវីទាំងពីរនឹងចុះអនុស្សារណៈយោគយល់គ្នា ដើម្បីធ្វើកិច្ចសហការគ្នាក្នុងវិស័យច្បាប់ និងបច្ចេកទេស។
កិច្ចប្រជុំបានបញ្ចប់ដោយបរិយាកាសរីករាយ។






**លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានពិភាក្សាការងារជាមួយឯកឧត្តម ចឹយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី**

នៅថ្ងៃចន្ទ ០៣ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានពិភាក្សាការងារនិងទទួលទានអាហារថ្ងៃត្រង់ជាមួយឯកឧត្តម ចឹយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស ម៉ាឡេស៊ី។ នៅក្នុងការទទួលទានអាហារនេះ លោកប្រធានគណៈមេធាវី និងលោកឯកអគ្គរាជទូតបានផ្តោតការពិភាក្សាយ៉ាងយកចិត្តទុកដាក់ពី "យុទ្ធសាស្ត្រ និងវិធានការចាំបាច់នានាដើម្បី ផ្តល់ជំនួយផ្នែកច្បាប់ដល់ពលករខ្មែរដែលធ្វើការនៅប្រទេសម៉ាឡេស៊ី។ "កិច្ចពិភាក្សា និងទទួល ទាននេះស្ថិតក្រោមបរិយាកាស រីករាយ ស្និទ្ធិស្នាល និងយោគយល់អធ្យាស្រ័យគួរជាទីមោទន។



## លោកមេធាវី គង់ សំអុន និងលោកមេធាវី កែ ប៊ុនធឿន បានចូលរួមប្រជុំសិក្សាស្វែងយល់ពីដំណើរការរបស់មណ្ឌលសេវាកម្មយុត្តិធម៌

នៅរសៀលថ្ងៃចន្ទ ០២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០២០ លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋាន ស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ និងលោកមេធាវី កែ ប៊ុនធឿន ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិបានចូលរួមប្រជុំសិក្សាស្វែងយល់ពីដំណើរការរបស់មណ្ឌលសេវាកម្មយុត្តិធម៌ ដើម្បីជួយលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ជាមួយគណៈមេធាវីជប៉ុននៅសាលាខណ្ឌ សែនសុខ រាជធានីភ្នំពេញ ។



## ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បាទទួលជួបពិភាក្សាជាមួយសហព័ន្ធមេធាវីជប៉ុន

នៅរសៀលថ្ងៃអង្គារ ០៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បាទទួលជួបពិភាក្សាជាមួយសហព័ន្ធមេធាវីជប៉ុន ប្រព្រឹត្តនៅគណៈមេធាវីកម្ពុជា លើគម្រោង "ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌" ដែលមានរបៀបវារៈដូចខាងក្រោម៖

- គម្រោង និងគោលការណ៍ លើគម្រោងកិច្ចសហប្រតិបត្តិការ
- ពេលវេលាលើការអនុវត្តគម្រោង

- ស្ថានភាពបច្ចុប្បន្នលើសិទ្ធិទទួលបានយុត្តិធម៌ នៅប្រទេសកម្ពុជា
- ការពិភាក្សាលម្អិតទៅលើសកម្មភាពគម្រោង
- សន្និសិទអន្តរជាតិដែលនឹងប្រព្រឹត្តទៅនៅ ខែមិថុនា

នៅក្នុងកិច្ចពិភាក្សានេះ សមភាគីទាំងពីរបានផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក លើគម្រោង "ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌" និងការអនុវត្តនៅកម្ពុជាដែលគណៈមេធាវីបានធ្វើកន្លងមក។

ចុងក្រោយនៃកិច្ចពិភាក្សានេះឯកឧត្តមប្រធានគណៈមេធាវី បានឯកភាពទទួលយកសំណើរបស់សហព័ន្ធមេធាវីជប៉ុនដើម្បីយកទៅពិចារណា និងដាក់នៅក្នុងសេចក្តីព្រាងចុះអនុស្សារណៈយោគយល់រវាងគណៈមេធាវីកម្ពុជា និងសហព័ន្ធមេធាវីជប៉ុន ដើម្បីចុះហត្ថលេខានាពេលអនាគត។





## ២. ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា

### សិក្ខាសាលាក្រោមប្រធានបទ " គំនូរឧស្សាហកម្ម និងការអនុវត្តនៅកម្ពុជា និងជប៉ុន"

នៅថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២០ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយ សមាគមកម្មសិទ្ធិបញ្ញាកម្ពុជាបាន រៀបចំសិក្ខាសាលាក្រោមប្រធានបទ "គំនូរឧស្សាហកម្ម និងការអនុវត្តនៅកម្ពុជា និងជប៉ុន" ក្រោម អធិបតីភាពឯកឧត្តម ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង ប្រធានសមាគមកម្មសិទ្ធិបញ្ញាកម្ពុជាសិក្ខាសាលានេះប្រារព្ធធ្វើឡើងនៅទីស្នាក់ការគណៈមេធាវី នៃ ព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងសិក្ខាសាលានេះ ក៏មានវាគ្មិនកិត្តិយសបានឡើងធ្វើបទបង្ហាញពី យន្តការនៃកិច្ច ការពារគំនូរឧស្សាហកម្មក្រោមច្បាប់កម្ពុជា ច្បាប់ស្តីពីការរចនា និងការអនុវត្តនៅប្រទេសជប៉ុន និង នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្មនៅកម្ពុជា។ ក្រៅអំពីការធ្វើបទបង្ហាញនេះ កម្មវិធីសិក្ខាសាលាក៏មាន នូវកម្មវិធីសំណួរចម្លើយទៅកាន់វាគ្មិនកិត្តិយស ដើម្បីជាការដោះស្រាយចម្ងល់ ជាការចែកចាយ ចំណេះដឹង និងការដកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមក។

ចុងបញ្ចប់នៃកម្មវិធី លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និង ផ្សព្វផ្សាយ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានឡើងថ្លែងចំណាប់អារម្មណ៍បិទកម្មវិធី និង បានបិទបញ្ចប់កម្មវិធីរបស់ខ្លួននៅវេលាម៉ោង ១២ ថ្ងៃត្រង់ នាថ្ងៃដដែលនោះ។



## ៣. ជង្រែកពីច្បាប់

### លោកមេធាវី គង់ សំអុន អញ្ជើញជាវាគ្មិនកិត្តិយលក្នុងការចែករំលែកចំណេះដឹងច្បាប់ស្តីពី "ការប៉ះពាល់ដល់អនីតិជន និងគ្រួសារ"

លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ នៃគណៈមេធាវីកម្ពុជា បានអញ្ជើញវាគ្មិនកិត្តិយស ក្នុងកម្មវិធីវិទ្យុសិទ្ធិមនុស្សកម្ពុជា លើប្រធានបទ "ការប៉ះពាល់ដល់អនីតិជននិងគ្រួសារ(១)" ។




### លោកមេធាវី ទៀង វុទ្ធា អញ្ជើញជាវាគ្មិនកិត្តិយលក្នុងការចែករំលែកចំណេះដឹងច្បាប់ក្រោមប្រធានបទ "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព"



## ៤. កិច្ចប្រជុំបុគ្គលិក

### លោកមេធាវី សួន វិសាល ប្រធាន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំបុគ្គលិក

នៅព្រឹកថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ ២០២០ នៅទីស្នាក់ការ គណៈមេធាវី ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធាន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារ និងដំណើរការ
រីកចម្រើនក្នុងអង្គភាពដែលមានរបៀបវារៈដូចខាងក្រោម៖

១.បើកកិច្ចប្រជុំ

២.រាយការណ៍សកម្មភាព និងសំនូមពរ

៣.មតិណែនាំនិងដំណោះស្រាយបញ្ហាប្រឈមនានា

៤.ផ្សេងៗ

កិច្ចប្រជុំនេះមានការចូលរួមពីបុគ្គលិកគ្រប់នាយកដ្ឋាន និងបុគ្គលិកការិយាល័យរបស់គណៈមេធាវីគ្រប់ជាន់ថ្នាក់។




## ៥. កិច្ចប្រជុំគណៈកម្មការជំនាញ

### លោកមេធាវី គង់ សំអុន បានដឹកនាំអង្គប្រជុំសម្រាប់គណៈកម្មការ ការស្រាវជ្រាវ និង កំណត់តម្លៃ វគ្គបណ្តុះបណ្តាលមេធាវី

នៅថ្ងៃអង្គារ ៥រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ ២០២០ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លោកមេធាវី គង់ សំអុន ប្រធាននាយក

ដ្ឋាន ស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ បានដឹកនាំអង្គប្រជុំ គណៈកម្មការ ការស្រាវជ្រាវ និងកំណត់តម្លៃវគ្គបណ្តុះបណ្តាលមេធាវី ជំនាញឯកទេសដែលមានរបៀបវារៈដូចជា៖

- ការបែងចែកការងាររបស់គណៈកម្មការ
- ការសិក្សាស្រាវជ្រាវមុខវិជ្ជាដែលត្រូវយកមកបណ្តុះបណ្តាល
- ផ្សេងៗ

កិច្ចប្រជុំនេះ បានបញ្ចប់ទៅដោយបរិយាកាសរីករាយ និងប្រកបដោយផលផ្លែផ្កាគួរជាទីមោទនៈ។




## ៦. ផ្សេងៗ

### ការជួបសំណេះសំណាលស្វែងយល់ពីគណៈមេធាវី និងការចូលប្រកបវិជ្ជាជីវៈមេធាវីនៅទីស្នាក់ការគណៈមេធាវី

នាថ្ងៃព្រហស្បត្តិ៍ ១៣ កើត ខែមាឃ ឆ្នាំ កុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៣:០០ រសៀល នៅទីស្នាក់ការគណៈមេធាវី លោកមេធាវីសួន វិសាល ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា រួមជាមួយលោកមេធាវី លីវ សុវណ្ណា អគ្គលេខាធិការរង នៃគណៈមេធាវីបានអនុញ្ញាតិឲ្យនិស្សិតមកពីសាកលវិទ្យាល័យ សៅអ៊ីសថ៍អេយសៀ មកពីខេត្តសៀមរាប បានជួបសំណេះសំណាលស្វែងយល់ពីគណៈមេធាវី និងការចូលប្រកបវិជ្ជាជីវៈមេធាវី ។





## ពិធីពិធីបិទវគ្គបណ្តុះបណ្តាលវគ្គសុក្រឹតការវគ្គទី៨ មេធាវីចូលប្រកបវិជ្ជាជីវៈមេធាវី

នៅរសៀលថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីពិធីបិទវគ្គបណ្តុះបណ្តាលវគ្គសុក្រឹតការដល់មេធាវីចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វគ្គទី៨ក្រោមអធិបតីភាពលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងពិធីបិទនេះ ក៏មានការចូលរួមពីលោកមេធាវី យឹម សារីប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងសិស្សវគ្គសុក្រឹតការវគ្គទី ៨ ចំនួន ១០០ នាក់ផងដែរ។ លោកអគ្គលេខាធិការគណៈមេធាវីក៏មានមតិផ្តាំផ្ញើដល់សិស្សមេធាវីទាំងអស់ដែលបញ្ចប់វគ្គសិក្សាថ្ងៃនេះ ចេញទៅប្រកបវិជ្ជាជីវៈប្រកបដោយសីលធម៌ខ្ពស់ និងជាមេធាវីប្រកបដោយវិជ្ជាជីវៈ ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ក្នុងសង្គមកម្ពុជា។






## ឯកឧត្តម សួន វិសាល បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយក្នុងការប្រារព្ធខួបគម្រប់ ៨ឆ្នាំ របស់ក្រុមហ៊ុនអៃយ៉ារ៉ា

នៅព្រឹកថ្ងៃចន្ទ ១ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ គណៈប្រតិភូនៃគណៈមេធាវី ដឹកនាំដោយឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយក្នុងការប្រារព្ធខួបគម្រប់៨ឆ្នាំ របស់ក្រុមហ៊ុនអៃយ៉ារ៉ា ដែលកម្មវិធីនេះបានរៀបចំធ្វើឡើងនៅមជ្ឈមណ្ឌលដឹព្រីមៀ

សែនសុខ រាជធានីភ្នំពេញ។ នៅក្នុងពិធីនោះក៏មានការចូលរួមពីបណ្តាសាខាចែឬកចាយនានារបស់ក្រុមហ៊ុន អៃយ៉ារ៉ានៅទូទាំងប្រទេសកម្ពុជាផង។




**ប្រសាសន៍ណែនាំរបស់លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អំពីការបង្ការការរីករាលដាលនៃមេរោគកូរ៉ូណា (COVID19)**

https://www.bakc.org.kh/index.php/km/2753-covid19



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី គង់ សំអុន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី ឡៀង ទុន្ធា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃឹម ច័ន្ទធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ និងបោះពុម្ព |
| ៥-លោកមេធាវី ខន សុខេង | ប្រធានការិ.ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោក ថា ប៊ុនថៃ | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៧-លោក ស្រេង សីហាប៊ុននុត | ជំនួយការ ការិ.ព័ត៌មានវិទ្យា |
| ៨-កញ្ញាមេធាវី តាន់ ចរណៃ | បណ្ណារក្ស |
| ៩-លោកមេធាវី ម៉ៅ តាន់អៀម | បណ្ណារក្ស |
| ១០-កញ្ញា វ៉ាត់ លាន | ស្ម័គ្រចិត្ត |
| ១១-លោក វ៉ាត និត្យ | ស្ម័គ្រចិត្ត |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា